ព្រះរាជបណ្ណាល័យកម្ពុជា

កម្ពុជសុរិយា

សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគម្រប់ពីរ

លេខ ៦

ក្រុងភ្នំពេញ

រោងពុម្ពរាជការ គូវែរណើម៉ង្ត

គ្រិ. ឆ្នាំ ១៩២៧

ព. ស. ២៤៧០

អ្នកទទួលខុសត្រូវ ជុំ-ម៉ៅ

បញ្ជីរឿង

ទំព័រ

១- អំពីចេតិយបុរាណក្នុងស្រុកលង្កា លោកហុការត៍ចាងហ្វាងក្រសួងរ៉ះរកក្សាច់របនាបុរាណក្នុងស្រុកលង្ការៀបរៀង ក្រុមការ ជុំ-ម៉ៅ ធ្វើរាជការនៅព្រះរាជបណ្ណាល័យកម្ពុជា:ប្រែជាភាសាខ្មែរ ៤៤៨

២- មរណានុស្សតិកម្មដ្ឋានពិស្ដារ ព្រះគ្រូវិមលបញ្ញា អ៊ុម ស៊ូរ អាចារ្យក្នុងព្រះរាជបណ្ណាល័យកម្ពុជា ប្រែចេញពីបាលីវិសុទ្ធិមគ្គ . . . ៤៥៥

៣-អំពីដើមកំណើតប្រាសាទអង្គរ (តរគ្គាពីខ្សែទី ៤) លោកល្វីហ្វ៊ីណូត៍ អាចារ្យបង្រៀនឧត្ដមវិជ្ជា សាលាកូឡែសដឺហ្វ្រង្សនៅក្រុងប៉ារីស ជាអ្នកអធិប្បាយក្រុមការ ជុំ ម៉ៅ ធ្វើរាជការនៅព្រះរាជបណ្ណាល័យកម្ពុជា ប្រែចេញជាភាសាខ្មែរ ៤៨២

៤- គតិលោក ឬ ច្បាប់ទូន្មានខ្លួន ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ រៀបរៀង . .

(អត្ថបទនេះ មិនបានចុះផ្សាយទេ ព្រោះមានបោះចេញជាសៀវភៅហើយ)

COMMISSION DES MŒURS & COUTUMES

សេចក្តីអធិប្បាយអំពីចេតិយបុរាណ

ក្នុងស្រុកលង្កា (សីឡង់)

លោក ហុការត៍

ជាងហ្វាងក្រសួងរិះរកក្បាច់ចេនាបុរាណ ក្នុងស្រុកលង្កា រៀបរៀង

ក្រុមការ ជុំ-ម៉ៅ

ធ្វើរាជការនៅព្រះរាជបណ្ណាល័យប្រែជាភាសាខ្មែរ

សេចក្តីពន្យល់ របស់ ម៉ាដឹមូអាហ្វែល ការប៉ុឡែស

អំពីរូបផ្តិតពុម្ពខ្លះដែលមានក្នុងសេចក្តីអធិប្បាយនៃលោក ហុការត៍

យើងបានដឹងតាមដែលមានសម្តែងក្នុងគម្ពីរមហាវង្ស ថាក្រុងប៉ោឡោនរុវ និងអនុរាធបុរ ជាក្រុងដែលមានកេរ្តិ៍ឈ្មោះក្នុងកោះលង្កា ក្នុងព្រះពុទ្ធសករាជ ១៣៨៩ មកដល់ ១៨៣១ ដូចយ៉ាងទីក្រុងអង្គរ ល្បីនាមឮឡើងក្នុងនគរខ្មែរ កាលក្នុងពុទ្ធសករាជ ១៣៤៥ ដល់ ១៨៤០ ដូច្នេះដែរ ។

គំនូរទី ១ (ឯ.ស. ៣២៨) ជាតំណាងចេតិយ ១ នៅក្នុងក្រុងប៉ោឡោនរុវ សាងក្នុងរវាងពុទ្ធសករាជ ១៦០៨ ។

គំនូរទី ២ (ឯ.ស. ៣២៧) ជាតំណាងចេតិយ ១ នៅមិហិន្តល សាងក្នុងរវាងពុទ្ធសករាជ ១៤៥០ មិហិន្តលជាភ្នំមួយ កម្ពស់ជាង ៣០០

ម៉ែត្រ ហើយឆ្ងាយពីក្រុងអនុរាធបុរ ចំនួនប្រហែលជា ១៤ គីឡូម៉ែត្រ នៅលើភ្នំនោះ ហើយដែលព្រះមហិន្ទត្ថេរ ជាបុត្រព្រះបាទអសោករាជ នាំព្រះពុទ្ធសាសនាពីស្រុកឥណ្ឌាទៅផ្សាយដល់អ្នកស្រុកលង្កា ក្នុងពុទ្ធសករាជ ១១៨៣ ។

គំនូរទី ៣ (ឯ.ស ៣៦៦) គឺសត្មាហ័លប្រាសាទ នៅក្នុងដំបន់ប៉ុឡោន្នារុវ សាងពីឥដ្ឋទាំងអស់ ចេតិយនេះ មានសណ្ឋានបែបផែនប្រ-ហែលគ្នា នឹងប្រាសាទសំបូរព្រៃគុក នៅចម្ងាយ ២៨ គីឡូម៉ែត្រពីកំពង់ធំ ដលសាងក្នុងរវាង ពុទ្ធសករាជ ១១៤៣ ។

គំនូរទី ៤ (ឯ.ស. ៣៦៤) គឺកន្ទែងប្រាសាទបុរាណដែលបាក់បែកអស់ នៅក្នុងក្រុងអនុរាធបុរ ។

គំនូរទី ៥ (ឯ.ស. ៣៤០) គឺគ័លវិហារ នៅក្នុងដំបន់ប៉ុឡោន្នារុវ វិហារនេះកើតដោយបដិមាករ និងទីសន្និបាតដែលឆ្លាក់ធ្វើឡើងដោយផែនថ្មតែ ១ ដុំ នៅខាងឆ្វេងមានព្រះពុទ្ធរូបផ្ចាញ់មារ ហើយតទៅទៀតមានទីសន្និបាត និងសសរ ៤ ហើយមានព្រះពុទ្ធរូប ១ អង្គឆ្លាក់ក្នុងផែនថ្ម ១ នៅខាងឆ្វេងទីសន្និបាតនោះ ឃើញមានរូបព្រះមហាអានន្ទឈរ ហើយឆ្ងាយពីនោះបន្តិច មានព្រះពុទ្ធរូបបរិនិព្វាន វិហារនេះតាំងនៅជាកណ្ដាលច្រូងព្រៃ ។

គំនូរទី ៦ (ឯ.ស.៣១៩) គឺប្រាសាទអវក្ក័ល នៅប្រាសាទនេះ

ឃើញមានសំណាមប្រហោង ដែលគេចោះច្រើនកន្លែង នៅលើជញ្ជាំង មានសណ្ឋានដូចគ្នា នឹងប្រាសាទនៅអង្គរដែរ ឯប្រហោងទាំងនេះ គេរកដើមឫសមិនទាន់ឃើញនៅឡើយ ។

គំនូរទី ៧ (ឯ.ស.៣១៧) គឺស្រះគិរិតល័ ។ ជាការមានប្រយោជន៍ត្រូវតែសម្គាល់ថា ទីក្រុងចាស់របស់ស្រុកលង្កា មានស្រះធំៗ ដូចយ៉ាងទីក្រុងចាស់ខ្មែរ ដែលមានបារាយណ៍នោះដែរ ។

ស ការប៉ុឡែស

អំពីបែបភាពនៃប្រាសាទផ្សេងៗក្នុងស្រុកលង្កា

នៅក្នុងស្រុកលង្កា ក៏ដូចជាក្នុងស្រុកឯទៀតដែរ អស់តាំងប្រាសាទ ដែលគេសាងឧទ្ទិសដល់ពុទ្ធសាសនានោះ ចែកចេញបានជា ២ បែប គឺ បែបតាន់និង បែបប្រហោង ។

ឯបែបតាន់ដែលគេសាងក្នុងស្រុកលង្កានោះ គឺជាព្រះស្តូប ឬ ចេតិយនោះឯង ឯរឿងរ៉ាវនៃចេតិយក្នុងស្រុកលង្កានោះ មិនជាមានប្រយោជន៍ប៉ុន្មានឡើយ ដោយហេតុថាក្នុងស្រុកនោះ តាំងពីច្រើនរយឆ្នាំហើយ គេកម្រនឹងផ្លាស់បែបដែលកសាងនេះណាស់ (មើលគំនូរលេខ ១ ង.ស. ៣២៨) សេចក្តីដែលមិនប្រែប្រួលផ្លាស់បែបនេះធ្វើឲ្យឃើញថា ស្រុកលង្កាកាន់យកទំនៀមទម្លាប់ ពីបុរាណឥតប្រែប្រួលឡើយ ។

ហាក់ដូចជាក្នុងរវាងឆ្នាំ ៩០០ ដែលគេបានកសាងចេតិយ មានដំបូលច្កុល់បន្តុបឡើង បានជាថាដូច្នេះ ព្រោះមិនទាន់ច្បាស់សកកដនៅឡើយ ដែលកសាងនេះប្រហែលជាពួកមហាយានទេ គេបានកសាងប៉ុន្តែគ្មានអ្វីបញ្ជាក់ឲ្យពិតសោះ (មើលគំនូរលេខ ៣ ង.ស.៣២៧) លុះដល់មកក្នុងឆ្នាំ ១២០០ ទើបឃើញមានបែបតាន់ពងបួនជ្រុងខ្ទះកើតឡើង ឥតមានអ្នកណាដឹងរឿងអ្វីឲ្យជាក់ប្រាកដ អំពីបែបនៃចេតិយនេះឡើយ ប៉ុន្តែបែបចេតិយនេះ ប្រាកដជាមកពីប្រទេសក្រៅឯទៀត ហើយឯចេតិយសត្តាហ៍ល នៅស្រុកបោលោន្នរុវនោះ កាលដើមមានពងខាងក្រោមបួន

ជ្រុង ហើយខាងលើ ៦ ជ្រុង ហើយគេកែប្រែពីបែបដើមមកតាំងមូលដូច មានគំនូរទី ៤ (ឯ ស.៣២៦) ធ្វើឲ្យឃើញថាគេកែមកដូចម្តេចស្រាប់ ។

រឿងក៉វនៃចេតិយដែលប្រហោងនោះ មានប្រយោជន៍ជាង ព្រោះបែបចេតិយតាំងនោះធ្វើប្លែក ៗ ឡើង តាមកាលតាមសម័យ ឯបែបដែលកសាងដំបូងនោះ មិនប្រាកដជាកើតក្នុងពេលណាឡើយ ប៉ុន្តែប្រហែលជាមិនមែនកើតមុនគ្រិស្តសករាជ ២០០ ឆ្នាំទេ ចេតិយតាំងនេះ ខាងជើងក្រោមគឺ គេលើកដីខ្ពស់ឡើងកង ៤ ជ្រុង ហើយរៀបឥដ្ឋនៅខឿនជុំវិញតែប៉ុណ្ណោះ ឥតមានចេនាអ្វីទៀតឡើយ ហើយនៅកន្លែងនោះ គេសាងជាតួចេតិយឡើង គឺសាងដោយយកដីមកបូកបង្ហាប់ ឬដោយយកឈើមកធ្វើ ដូចជាគេបានប្រទះឃើញ ជាច្រើននៅដល់សព្វថ្ងៃនេះ ។ តើបែបនេះឯង ជាបែបថ្មីដែលផ្សាយមកពីស្រុកឥណ្ឌា ក្នុងរវាងឆ្នាំ ១០០ ដល់ឆ្នាំ ១០០០ ឬអ្វី ឬមួយក៏ចេតិយធ្វើដោយដីបូកនេះ កាលជាន់ដើមគេសាងភ្ជាប់នឹងដីតែម្តង ឥតមានខឿនកល់ទេ ឬអ្វី ។

ឯខឿននេះ តាមធម្មតា ច្រើនតែមាន ២ គឺខឿនទី ១ តែងតែនៅពីខាងកើត គឺជាមណ្ឌប ឯខឿនទី ២ គឺតួអាសនៈនោះឯង ។

លុះពេលក្រោយមកទៀត គេយកថ្មដែលគេរំលីង មកចេនាឡើង គេគ្រាន់តែយកថ្មមកតម្រៀបបន្តុបៗ ឥតមានបែបផែនអ្វីឡើយ ហើយចេតិយក៏គ្រាន់តែតូចទាបចុះ ប៉ុន្តែថ្មដែលគេប្រើការនោះធំៗណាស់ ឯថ្នាក់ខាងក្រោមនោះធ្វើឲ្យខ្ពស់ឡើង ហើយដើម្បីនឹងខ្ទង់ពីមណ្ឌបទៅឯទី

អាសនៈនោះ លុះតែមានស្ពាន ១ ទើបចូលទៅបាន ។

កន្លងពីនោះយូរមក គេធ្វើចេតិយកាន់តែធំៗឡើង ហើយវេទាគុបតែង ឲ្យល្អជាងដើមបន្តិចៗឡើង គេបានធ្វើពុម្ពបែបជម្ពាខ្ញុះ (មើលគំនូរលេខ ឯ.ស. ៣២៤) តមកទៀតការតុបតែងកាន់តែចម្រើនល្អឡើងក្បាច់ចម្លាក់អ្នកស្រុកលង្កាក៏កាន់តែកើតឡើងទៀត ដែលគេច្រើនវេទាគុបតែងជាងគេនោះគឺចេតិយ ដែលមានរូបរាងដូចជាចំហៀងព្រះចន្ទ្រ ដែលថតជាប់មកនេះ គឺជាចេតិយដែលល្អជាងគេនោះឯង ក្នុងកាលជាន់នោះពងប្រាសាទដែលមានដំបូលពាលកបស្មើ ក៏បាត់អស់ទៅ មុខគួរឲ្យមានសេចក្តីឆ្ងល់ ។

លុះមកដល់រវាងឆ្នាំ ១២០០ បែបវិហារស្តូបរាងលើនេះក៏គេបោះបង់ចោលទៅទៀត ទៅបានបែបរាងទ្រវែងធ្វើពីឥដ្ឋមកវិញ ទំនងជាធ្វើតាមលំអានសាសនាហិណ្ឌូ វិហារស្តូបទាំងនេះមានដើមបុសជាមួយគ្នានឹងវិហារស្តូប ៤ ជ្រុងនោះដែរ បានជាថាដូចនេះព្រោះគេបានស្គាល់ហាត់ដោះដើមដូចគ្នា ប៉ុន្តែមកធ្វើភាពសណ្ឋានឲ្យផ្សេងគ្នាទៅ ឯបែបទី ១ នោះមិនទាន់បាត់នៅឡើយទេ តែច្រើនឃើញមានតែក្នុងស្រុកស្រែ ជាងស្រុកក្រុង ព្រោះគេមិនសូវរកបាន ដោយហេតុនេះបានជាឃើញមានជាច្រើននៅក្នុងស្រុកកន្ទី គេបានទាំងឃើញបែបវិហារស្តូប ២ ដែរ មានដំបូលតាប ៤ ជាន់ផង ហើយប្រហែលជានៅមានទៀត ដែលមិនទាន់បានឃើញ ប៉ុន្តែក្នុងសម័យឥឡូវស្ទើរតែគ្រប់ចេតិយទាំងអស់ គេសាងមិនឲ្យមាន

មណ្ឌបឡើយ ឯចេតិយនៅស្រុកកន្ទីនោះ ដំបូលកបតាំង ២ ជាប់គ្នាទៅវិញ ។

នៅមានបែបចេតិយម៉្យាងទៀតដែលហៅថាគុក (មើលគំនូរលេខ ឯ.ស ៣២០) ឯចេតិយគុកនេះមិនសូវមានធ្វើសុទ្ធតាំងមូលឡើយ ច្រើនតែសាងលើទីដែលមានភាពសណ្ឋាន ទំនងជាចេតិយស្រាប់ ឧបមាដូចជាមានថ្មខ្ពង់ទៅ ហើយគេទៅធ្វើជាផ្ចាំងភ្ជាប់ដោយដីឥដ្ឋ ឬ ដោយឥដ្ឋ ព្រោះក្នុងជាន់ដើម គេកម្រធ្វើដោយថ្មណាស់ គ្រាន់តែធ្វើប៉ុណ្ណោះ ក៏កើតជាតួវិហារឡើង (មើលគំនូរលេខ ៦ ឯ.ស. ៣១៩) ។

ឯចំណែកគេហស្ថានវិញនោះ មិនឃើញមានបែបសណ្ឋានអ្វីជាស្តុកស្តម្ភឡើយ ឃើញមានតែស្តេចបាពក្រមពាហុទី ១ ក្នុងឆ្នាំ ១២០០ ប៉ុណ្ណោះ ដែលបានសាងប្រាសាទសម្រាប់គង់យ៉ាងល្អ ដូចជាព្រះវិហារ ឯការជាធំដែលគួរសម្គាល់នៅក្នុងស្រុកលង្កានោះ គឺការជីកទំនប់ទឹកនោះឯង ប៉ុន្តែគួរស្តាយណាស់ដែលរូបថតតាំងប៉ុន្មាន មិនបានជាប់កន្លែងទុកទឹកទាំងនេះ ទឹកនេះហើយ ដែលអាចនឹងចិញ្ចឹមបណ្តាជន ជាច្រើនក្នុងតំបន់គ្មានផ្លូវទឹក ឲ្យរស់ជីវិតបានរៀងរាល់ឆ្នាំ (មើលគំនូរ លេខ ៧ ឯ.ស. ៣១៧) ។

ហុការ៍

មរណានុស្សតិកម្មដ្ឋានពិស្ដារ

ព្រះគ្រូវិមលបញ្ញា អ៊ុំ ស៊ូរ

អាចារ្យក្នុងព្រះរាជបណ្ណាល័យកម្ពុជា

ប្រែចេញពីបាលីវិសុទ្ធិមគ្គ

-១-

និងវិនិច្ឆ័យក្នុងមរណានុស្សតិកម្មដ្ឋាននិទ្ទេស

តត្ថមរណសតិយាភាវនានិទ្ទេសេ ក្នុងមរណានុស្សតិភាវនានិទ្ទេស នោះ មានសេចក្ដីថា ព្រះយោគាវចរនឹងចម្រើននូវមរណានុស្សតិកម្មដ្ឋាន នោះ គប្បីរលឹកដល់សេចក្ដីស្លាប់ ឲ្យជានិច្ចជាប់នៅក្នុងសន្ដាន ។

ឯមរណៈនោះ សំដៅយកសេចក្ដីដែលដាច់ជីវិតិន្ទ្រិយ ដែលមានកំណត់ដោយភពតែ ១ គឺថាកើតឡើងក្នុងភពណា ជាសត្វមានជីវិតហើយ ដល់ចុតិទម្លាយខន្ធសូន្យដាច់ជីវិតិន្ទ្រិយ ទៅចាកភពនោះបានឈ្មោះថា មរណៈ សេចក្ដីមរណៈយ៉ាងនេះ គួរនឹងយកមកជាអារម្មណ៍នៃមរណានុស្សតិកម្មដ្ឋានបាន ។

ឯមរណៈមាន ៣ ប្រការទៀតគឺ សមុច្ឆេទមរណៈ, ខណិកមរណៈ, សម្មតិមរណៈ ។ មរណៈទាំង ៣ នេះ មិនគួរនឹងយកមកជាអារម្មណ៍នៃមរណា-

នុស្សតិកម្មដ្ឋានឡើយ សមុច្ឆេទមរណនោះ បានខាងព្រះអរហន្ត ដែលកាត់បង់នូវវដ្តទុក្ខ កិច្ចដែលសម្រេចដល់ព្រះអរហន្ត កាត់បង់នូវទុក្ខក្នុងសង្សារវដ្តបាននោះ ចាត់ជាមរណប្រការ ១ ហៅថាសមុច្ឆេទមរណ ខណិកមរណនោះ បានខាងសង្ខារធម៌ដែលរលត់រលាយគ្រប់ៗខន្ធ គឺថាចិត្តនិងចេតសិក ដែលកើតឡើងជាឧប្បាទខណ តាំងនៅជាឋិតិខណ រលត់ទៅជាភង្គខណ នោះចាត់ជាមរណប្រការ ១ ហៅថាខណិកមរណ សម្មុតិមរណនោះ បានខាងសេចក្តីស្លាប់ ដែលលោកសម្មតិ ដោយលោកពោលហៅថាដើមឈើស្លាប់ ទង់ដែងស្លាប់ ដែកស្លាប់ជាដើម ចាត់ជាមរណប្រការ ១ ហៅថាសម្មុតិមរណ ក៏មរណទាំង ៣ ប្រការនេះ ព្រះយោគាវចរ កុំប្រាថ្នាយកមកជាអារម្មណ៍ ក្នុងកាលដែលចម្រើនមរណ-នុស្សតិកម្មដ្ឋាននោះឡើយ មរណដែលគួរនឹងយកមកជាអារម្មណ៍នោះ ព្រះអដ្ឋកថាប្រាថ្នាយកមរណៈ ២ ប្រការ គឺ កាលមរណ ១ អកាលមរណ ១ កាលមរណនោះ គឺស្លាប់ដោយអស់បុណ្យអស់អាយុ អធិប្បាយថាសត្វទាំងពួងដែលមានកុសល ជាជនកកម្មនាំឲ្យបដិសន្ធិ ក្នុងទីដែលជាសុខ បើកុសលដែលជាឧបត្ថម្ភកគាំទ្រនោះ មិនបានទំនុកបម្រុងហូតទៅ បើទុកជាមានបច្ច័យគឺអាហារដែលតអាយុនោះនៅមានបរិបូណ៌ក្តី ក៏គង់មិនអាចនឹងវឌ្ឍនាការចម្រើនទៅបាន និងដល់នូវកិរិយាច្យុតិ ចាកខន្ធ ដាច់ជីវិត-ន្ទ្រិយ ព្រោះហេតុតែកុសល ឧបត្ថម្ភកតទៅពុំបាន មរណៈយ៉ាងនេះហៅថា បុញ្ញក្ខយមរណៈ គឺស្លាប់ដោយអស់បុណ្យ មានពាក្យដីកាចារ្យចូល

មកថា បុញ្ញក្ខយមរណ ស្លាប់ដោយអស់បុណ្យនេះថា ដោយសត្វដែលកើតក្នុងសម្បត្តិភព គឺភពបរិបូណ៌ដោយសម្បត្តិ ថាបើសត្វដែលកើតក្នុងវិបត្តិភព គឺភពប្រកបដោយសេចក្តីទុក្ខលំបាកដកបដល់អស់បាប អស់អកុសលកម្មនៃខ្លួន ហើយទើបធ្វើកាលកិរិយាចាកវិបត្តិភពនោះទៅ មរណយ៉ាងនេះហៅថា បាបក្ខយមរណ ស្លាប់ដោយអស់បាប ។

ឯអាយុក្ខយមរណនោះ គឺស្លាប់ដោយអស់អាយុនោះ ព្រះអដ្ឋកថាលោកពោលថា សត្វដែលកេតគតិសម្បត្តិ, កាលសម្បតិ, អាហារសម្បត្តិមិនបាន គឺមិនបានមានគតិបរិបូណ៌ដូចទេវតា ដែលបរិបូណ៌ដោយគតិ មិនបានមានកាលដ៏បរិបូណ៌ដូចបុគ្គលក្នុងបឋមកប្ប ដែលបរិបូណ៌ដោយកាល មិនបានមានអាហារដ៏បរិបូណ៌ដូចជាទ់ក្នុងឧត្តរកុរុទ្វីប ដែលបរិបូណ៌ដោយអាហារ មានអាយុតិចប្រមាណ ១០០ ឆ្នាំ ដូចមនុស្សប្រុសស្រីក្នុងកាលសព្វថ្ងៃនេះក្តី សត្វដែលបរិបូណ៌ដោយកាល និងអាហារ និងអាយុយឺនច្រើនជាង ១ សែនឆ្នាំនោះក្តី តែបណ្តាសត្វដែលស្ថិតនៅដកបដល់អស់អាយុហើយ ទើបធ្វើកាលកិរិយាទៅតាំងប៉ុន្មាន បានឈ្មោះថាអាយុក្ខយមរណដូចគ្នាតាំងអស់ អ្នកប្រាជ្ញគប្បីចូលចិត្តថា សត្វដែលអស់បុណ្យ អស់បាប អស់អាយុ ហើយស្លាប់ទៅនោះ បានឈ្មោះថាកាលមរណ គឺស្លាប់ក្នុងកាលដ៏គួរគប្បីស្លាប់ ។

ឯអកាលមរណ គឺស្លាប់ក្នុងកាលដ៏មិនសមគួរនឹងស្លាប់នោះ អធិប្បាយថា សត្វតាំងឡាយដែលមានខន្ធបែកធ្លាយដោយអំណាចឧបច្ឆេទកកម្ម គឺ

កម្មចូលទៅជិតផ្តាច់បង់នូវជីវិត ដូចស្តេចទុសិមារពេជនិងស្តេចកលាបុកជ ជាដើមដែលប្រទូសរ៉ាយដល់ខន្តីវាទីតាបសហើយផែនដីបើកចន្លោះឲ្យធ្លាក់ ចុះទៅក្នុងអវិចីនរកនោះ បានឈ្មោះថាអកាលមរណៈ។នេះគឺស្លាប់ក្នុងកាល មិនគួរស្លាប់ មិនតែម៉្យាងប៉ុណ្ណោះ សត្វទាំងឡាយដែលមានបាបណាក កម្ម មានគេមកកាប់ មកចាក់ឲ្យស្លាប់ ដោយគ្រឿងសស្ត្រាវុធធ្វើកាល កិរិយាទៅដោយព្យាយាមនៃបុគ្គលដទៃ ឬឲ្យកើតមានអកុសលចិត្តប្រហារ ជីវិតនៃខ្លួនដោយខ្លួនឯងក្តី សេចក្តីស្លាប់យ៉ាងនេះក៏បានឈ្មោះថាអកាល មរណៈដែរ ក៏មរណៈទាំង ២ ប្រការ គឺកាលមរណៈ និងអកាលមរណៈ មានន័យដូចពណ៌នាមកនេះ សមគួរនឹងយកមកជាអារម្មណ៍ក្នុងកាលដែល នឹងចម្រើនមរណានុស្សតិកម្មដ្ឋាននោះឯង ។

តំ ភាវេន្តេន រហោគតេន ។ល។ យោនិសោ មន-
សិការោ បវត្តេតព្វោ ។

សេចក្តីថា ព្រះយោគាវចរអ្នកប្រាថ្នា នឹងចម្រើននូវមរណានុស្សតិ-កម្មដ្ឋាននោះ គប្បីចូលទៅកាន់ទីសេនាសនដ៏ស្ងាត់នៅតែម្នាក់ឯង ហើយ គប្បីបរិកម្មថា មរណំ ភវិស្សតិ ជីវិតិន្ទ្រិយំ ឧបច្ឆិជ្ជិស្សតិ សេចក្តីស្លាប់នឹងមានជីវិតិន្ទ្រិយនឹងដាច់ ដូច្នេះក៏បាន ឬថា មរណំ ៗ សេច ក្តីស្លាប់ៗដូច្នេះក៏បានកាលដែលនឹងធ្វើ បរិកម្មនោះគប្បីតាំងមនសិការគឺធ្វើ ទុកក្នុងចិត្តជាឧបាយឲ្យមាំ កុំធ្វើមនសិការដោយឧបាយគ្មាន មានពាក្យដ៏-

កាចារ្យវិសជ្ជនាថាដែលឲ្យធ្វើមនសិការកំណត់ដោយឧបាយ គឺថាឲ្យមានសតិនិងបញ្ញាពិចារណាឲ្យឃើញធម្មសំវេគថា សេចក្តីស្លាប់នោះនឹងមានដល់យើងដោយពិត ជីវិតនៃយើងនេះនឹងដាច់ដោយពិត គប្បីពិចារណាឲ្យឃើញសំវេគដូច្នេះ កុំបរិកម្មទៅតែមាត់ទទេចិត្តមិនមានសំវេគសោះ បើបរិកម្មទៅតែមាត់ហើយមិនបានតាំងបញ្ញាចុះពិចារណា ឲ្យឃើញធម្មសំ-វេគក្នុងសេចក្តីស្លាប់នោះទេ ក៏បានឈ្មោះថាធ្វើមនសិការដោយរកឧបាយគ្មាន កាលបើព្រះយោគាវចរប្រព្រឹត្តនូវកិច្ចមនសិការ ដោយរកឧបាយគ្មាននោះ ខណកាលរលឹកដល់សេចក្តីស្លាប់ នៃបុគ្គលដែលជាទីស្រឡាញ់ ក៏កើតសេចក្តីស្រណោះ ឧបមាដូចបុគ្គលដែលរឭកដល់មាតាបង្កើត និងកូនដែលជាទីស្រឡាញ់ដែលដល់នូវទីតនិច្ចកម្មកន្លងទៅ ក៏នឹងកើតសេចក្តីសោកសេចក្តីខ្សឹកខ្សួល កាលបើរឭកដល់សេចក្តីស្លាប់របស់ជន ដែលខ្លួនស្អប់ក្តីមិនស្រឡាញ់ ក៏នឹងកើតសេចក្តីត្រេកអរទៅវិញ ដូចជនដែលមានពៀររលឹកដល់សេចក្តីស្លាប់នៃគ្នា និង គ្នា កាលបើរលឹកដល់សេចក្តីស្លាប់ នៃបុគ្គលដែលខ្លួនមិនស្អប់មិនស្រឡាញ់នោះ ក៏នឹងព្រងើយ ៗ មិនមានសេចក្តីសំវេគដូចឆវទាហិកជនគឺអ្នកសម្រាប់ដុតខ្មោច កាលបើឃើញសាកអសុភហើយ នឹង រកសេចក្តីសំវេគគ្មាន ថាបើរលឹកដល់សេចក្តីស្លាប់របស់ខ្លួនវិញ ក៏កើតសេចក្តីតក់ស្លុតក្នុងចិត្ត ដូចបុគ្គលដែលមានសន្តានប្រកបដោយសេចក្តីខ្លាចច្រើន កាលណាបើបានឃើញពេជ្ឈឃាដ កាន់នូវដាវលើកឡើងគ្រវីក្នុងទីចំពោះមុខ ក៏មានចិត្តនោះ

តក់ស្លុតក្រៃពេក សេចក្ដីនេះអ្នកប្រាជ្ញគប្បីសន្និដ្ឋានក្នុងចិត្តថា ហេតុដែលនឹងឲ្យកើតសេចក្ដីសោយសោកក្ដី សេចក្ដីត្រេកអរក្ដី សេចក្ដីរកសំវេគគ្មានក្ដី សេចក្ដីតក់ស្លុតក្នុងចិត្តក្ដី ហេតុទាំងអស់នេះក៏អាស្រ័យអំពីកិរិយាប្រាសចាកសតិបញ្ញារកសំវេគគ្មាន ព្រោះធ្វើមនសិការដោយរកឧបាយគ្មាន បរិកម្មថា មរណំ ៗ នោះត្រឹមតែមាត់ទទេ មិនបានយកសតិបញ្ញាប្រកបចូលឲ្យឃើញធម្មសំវេគពិត ៗ ផង ត្រឡប់ទៅជាដូច្នោះបាន បើធ្វើមនសិការដោយឧបាយញុំាងសតិបញ្ញា ឲ្យជ្រៀតជ្រែកចូលបានទានធម្មសំវេគ តាំងនៅក្នុងសន្ដានហើយឯណាឡើយ ក៏នឹងទៅជាដូច្នោះបាន នឹងចម្រើនជាគុណវុឌ្ឍិដ៏ប្រសើរ បើទុកជាលើកដល់សេចក្ដីស្លាប់នៃបុគ្គលដ៏ជាទីស្រឡាញ់ក្ដី ក៏មិនសោយសោកលើកដល់សេចក្ដីស្លាប់នៃបុគ្គលមានពៀរដែលខ្លួនស្អប់ខ្ពើមក្ដី ក៏មិនត្រេកអរ លើកដល់សេចក្ដីស្លាប់នៃបុគ្គលដែលខ្លួនមិនស្អប់ មិនស្រឡាញ់ក្ដី ក៏មិនបានព្រងើយគង់នឹងកើតសេចក្ដីសំវេគបរិបូណ៌ទៅក្នុងសន្ដាន បើទុកជាលើកដល់សេចក្ដីស្លាប់នៃខ្លួនទៀត ក៏គង់មិនតក់ស្លុតប៉ុន្មាន និងប្រាសចាកសេចក្ដីតក់ស្លុតទៅបាន ។

តស្មា តត្ថ តត្ថ ហតមតសត្តេ ឱលោកេត្វា ទិដ្ឋបុព្វ-សម្បត្តីនំ មតានំ សត្តានំ មរណំ អាវជ្ជិត្វា សតិញ្ច សំវេគញ្ច ញាណញ្ច យោជេត្វា មរណំ ភវិស្សតិ ។

ហេតុដូច្នោះ ព្រះយោគាវចរដែលចម្រើនមរណានុស្សតិកម្មដ្ឋាននោះ

គប្បីពិចារណានូវសេចក្ដីស្លាប់នៃសត្វទាំងឡាយ ដែលជាសត្រូវសម្លាប់ក្ដី ស្លាប់ឯងក្ដី ដែលគេចោលនៅក្នុងទីទាំងពួង មានទីស្មសានជាដើមដែលខ្លួនបានឃើញអំពីមុន គប្បីពិចារណាយកមកជាអារម្មណ៍ ក្នុងកាលដែលចម្រើនមរណានុស្សតិកម្មដ្ឋាននោះ សតិញ្ច ញាណញ្ច សំវេគ-ញ្ច យោជេត្វា គប្បីធ្វើមនសិការដោយឧបាយ ញុំាងសតិនិងបញ្ញា និងធម្មសំវេគឲ្យកើតឡើងហើយ គប្បីធ្វើបរិកម្មដោយន័យមានដើមថា មរណំ ភវិស្សតិ ជីវិតិន្ទ្រិយំ ឧបច្ឆិជ្ជិស្សតិ (សេចក្ដីប្រែដូចមុន) កាលបើព្រះយោគាវចរប្រព្រឹត្តដោយវិធី ដែលព្រះអដ្ឋកថាចារ្យសម្ដែងទុកដូច្នេះ ពួកខ្លះដែលមានបញ្ញិន្ទ្រិយមុតក្លានោះ ក៏អាចឃាត់បង់នូវនីវរណធម៌ទាំង ៥ មានកាមច្ឆន្ទជាដើម និងមានមរណារម្មណ៍តាំងមាំនិងបានសម្រេចឧបចារសមាធិ មិនបានព្រួយលំបាកពេកព្រោះមានបញ្ញិន្ទ្រិយមុតក្លា ។

ឯព្រះយោគាវចរដែលមានបញ្ញិន្ទ្រិយ មិនបានមុតក្លា ក៏មិនបានសម្រេចកិច្ចនៃកម្មដ្ឋានវិធីប៉ុណ្ណោះទេ បើមានប្រាថ្នាចម្រើនក្នុងមរណានុស្សតិកម្មដ្ឋានតទៅ ក៏គប្បីរលឹកដល់សេចក្ដីស្លាប់ដោយអាការ ៨ គឺ ៖

១. វធកបច្ចុបដ្ឋាន ឲ្យព្រះយោគាវចររលឹកដល់សេចក្ដីស្លាប់ឲ្យឃើញប្រាកដ ដូចនាយពេជ្ឈឃាដដែលមានដៃកាន់ដាវដ៏មុត មានពាក្យបុច្ឆាសួរថា ហេតុអ្វីទើបឲ្យរលឹកដូច្នេះ វិសជ្ជនាថា បានជាឲ្យរលឹកយ៉ាង

ដូច្នេះនោះ ព្រោះឡើយឃើញថា ការដែលកើតនិងស្លាប់នោះមកព្រមគ្នា
សត្វទាំងឡាយដែលកើតមកក្នុងលោកនេះ តែងមានជរានិងខណិកមរណ
ជាប់ប្រជិតជាមួយនឹងខ្លួនមកគ្រប់រូបគ្រប់នាម យថាហិ អហិច្ឆត្តកំ
មកុលំ មត្ថកេ បំសុំ គហេត្វាវ ឧគ្គច្ឆតិ ប្រៀបដូចក្រពុំផ្សិត
ដែលដុលឡើងផុតពីផែនដី តែងនាំយកមកនូវធូលីអាចម៍ដីឡើងមកផង
តេសំ បដិសន្ធិចិត្តំ ឧប្បាទានន្តរមេវ ជរំ បត្វា សត្វទាំងឡាយ
ដែលកាន់យកនូវបដិសន្ធិកំណើតក្នុងលោកនេះចាប់ដើមអំពីបដិសន្ធិហើយ
ក្នុងលំដាប់ឧប្បាទខណនៃបដិសន្ធិចិត្តនោះ ក៏ដល់នូវសេចក្តីជរានិងមរណៗ
ជាប់ជិតតាមមកជាមួយនឹងខ្លួន បព្វតសិខរតោ បតិតោ សិលា-
វិយ ប្រៀបដូចដុំថ្ម ដែលបែកធ្លាក់ចុះចាកកំពូលភ្នំ តែងកាន់យកនូវ
ដើមឈើ និងគុម្ពស្មៅ ដែលជាប់ជាមួយនឹងខ្លួនមកផង មរណំ បិ-
សហជាតិយា អាគតំ កិរិយាកើតនិងស្លាប់នេះ ជាប់មកព្រមគ្នា
ជាមួយសហជាតធម៌ ព្រោះថាកើតមានហើយ ស្លាប់ក៏មានផង បុគ្គល
ដែលកើតមកនេះ តែងនឹងស្លាប់ទៅវិញដោយពិត ចាប់ដើមអំពីកើតឡើង
ហើយ ក៏បែរមុខចំពោះទៅកាន់សេចក្តីស្លាប់មែនពិត ដូចព្រះអាទិត្យ
ឧគ្គមនាការរះឡើងហើយក៏បែរមុខចំពោះទៅកាន់ទីអស្តង្គត មិនបានថយ
ក្រោយត្រឡប់ចាកវិថីដំណើរនោះឡើយ មួយទៀតឧបមាដូច ទឹក

ដែលហូរចុះមកអំពីភ្នំ ប្រព្រឹត្តទៅរហ័សមិនអាចត្រឡប់ក្រោយ តែបណ្តាដើមឈើនិងដើមស្មៅដែលធ្លាក់ចុះមកក្នុងខ្សែទឹកនោះ សូម្បីតែវត្ថុណា ១ នឹងអាចត្រឡប់វិលក្រោយគ្មានឡើយ សេចក្តីនេះមានឧបមាដូចម្តេចមិញ ថាមានឧបមេយ្យដូចអាយុសង្ខារសត្វទាំងពួង ដែលកន្លងទៅ ៗ មិនត្រឡប់ក្រោយ តាំងមុខចំពោះទៅកាន់សេចក្តីស្លាប់ មិនរេរាដូច្នោះឯង ហេតុដូច្នោះ ព្រះសម្មាសម្ពុទ្ធសំដែងទុកថា យមេករត្តឹ បឋមំ គព្ភេ វសតិ មាណវោ អព្ភុដ្ឋិតោវ សោ យាតិ ស គច្ឆំ ន និវត្តតិ ថាសត្វដែលទៅក្នុងគភ៌នៃមាតា ចាប់ដើមអំពីខណៈតាំងបដិសន្ធិ ក្នុងវេលាពេលរាត្រីនោះ ហើយក៏តាំងប្រែទៅ ៗ កាលដើមជាកលលរូប ហើយប្រែទៅជា អព្ពុទ ជាបេសិ ជាឃន ចេះតែប្រែទៅ ៗ ដរាប់លើមរណភាពជាទីបំផុត នឹងរកទៀងរកប្រាកដមិនមាន ប្រៀបដូចពពកដែលតាំងឡើងហើយ ក៏ដល់នូវការរំលាយបាត់ទៅ ៗ ដរាបដល់សូន្យបាត់ ៗ

មានពាក្យដីកាចារ្យរិសជ្ជនាថា ដែលមានព្រះពុទ្ធភាសិតថា សត្វដែលតាំងបដិសន្ធិ ក្នុងវេលារាត្រីយប់នោះ គឺថាដោយ យេភុយ្យន័យ ថាជម្មតាសត្វដែលកាន់យកបដិសន្ធិ ក្នុងវេលាយប់នេះមានដោយច្រើន ដែលនឹងកាន់យកបដិសន្ធិក្នុងវេលាកណ្តាលថ្ងៃនោះមានដោយតិច ហេតុដូច្នោះអ្នកប្រាជ្ញគប្បីចូលចិត្តថា តើសត្វនោះព្រះអង្គសម្តែងដោយ យេភុយ្យន័យ ឯអាយុនៃសត្វដែលកន្លងទៅ ៗ ដោយន័យដូចពណ៌នាមក

ដូច្នេះនោះ ព្រោះឲ្យឃើញថា ការដែលកើតនិងស្លាប់នោះមកព្រមគ្នា សត្វទាំងឡាយដែលកើតមកក្នុងលោកនេះ តែងមានជរានិងខណិកមរណ ជាប់ប្រជិតជាមួយនឹងខ្លួនមកគ្រប់រូបគ្រប់នាម យថា ហិ អហិច្ឆត្តកំ មកុលំ មត្ថកេន បំសុំ គហេត្វាវ ឧគ្គច្ឆតិ ប្រៀបដូចផ្សិត ដែលដុះឡើងផុតពីផែនដី តែងនាំយកមកនូវធូលីអាចម៍ដីឡើងមកផង តេសំ បដិសន្ធិចិត្តំ ឧប្បាទានន្តរមេវ ជរំ បត្វា សត្វទាំងឡាយ ដែលកាន់យកនូវបដិសន្ធិកំណើតក្នុងលោកនេះចាប់ដើមអំពីបដិសន្ធិហើយ ក្នុងលំដាប់ឧប្បាទខណៈនៃបដិសន្ធិចិត្តនោះក៏ដល់នូវសេចក្ដីជរានិងមរណៈ ជាប់ជិតតាមមកជាមួយនឹងខ្លួន បព្វតសិខរតោ បតិតា សិលា-វិយ ប្រៀបដូចដុំថ្ម ដែលបែកធ្លាក់ចុះចាកកំពូលភ្នំ តែងកាន់យកនូវ ដើមឈើ និង គុម្ពស្មៅ ដែលជាប់ជាមួយនឹងខ្លួនមកផង មរណំ បិ-សហ ជាតិយា អាគតំ កិរិយាកើតនិងស្លាប់នេះ ជាប់មកព្រមគ្នា ជាមួយសហជាតធម៌ ព្រោះថាកើតមានហើយ ស្លាប់ក៏មានផង បុគ្គល ដែលកើតមកនេះ តែងនឹងស្លាប់ទៅវិញដោយពិត ចាប់ដើមអំពីកើតឡើង ហើយ ក៏បែរមុខចំពោះទៅកាន់សេចក្ដីស្លាប់មែនពិត ដូចព្រះអាទិត្យ ឧគ្គមនាការរះឡើងហើយក៏បែរមុខចំពោះទៅកាន់ទីអស្តង្គត មិនមានថយ ក្រោយត្រឡប់ចាកវិថីដំណើរនោះឡើយ ម្យ៉ាងទៀតឧបមាដូច ទឹក

ដែលហូរចុះមកអំពីភ្នំ ប្រព្រឹត្តទៅហើយមិនអាចត្រឡប់ក្រោយ តែបណ្ដាដើមឈើនិងដើមស្មៅដែលធ្លាក់ចុះមកក្នុងខ្សែទឹកនោះ សូម្បីតែវត្ថុណា ១ នឹងអាចត្រឡប់វិលក្រោយគ្មានឡើយ សេចក្ដីនេះមានឧបមាដូចម្ដេចមិញ ថាមានឧបមេយ្យដូចអាយុសង្ខារសត្វទាំងពួង ដែលកន្លងទៅ ៗ មិនត្រឡប់ក្រោយ តាំងមុខចំពោះទៅកាន់សេចក្ដីស្លាប់ មិនរេកដូច្នោះឯង ហេតុដូច្នោះ ព្រះសម្មាសម្ពុទ្ធសំដែងទុកថា យមេករត្តឹ បឋមំ គព្ភេ វសតិ មានវោ អព្ភុដ្ឋិតោវ សោ យាតិ ស គច្ឆំ ន និវត្តតីតិ ថាសត្វដែលទៅក្នុងគតិនៃមាតា ចាប់ដើមអំពីខណៈតាំងបដិសន្ធិ ក្នុងវេលារាត្រីនោះ ហើយក៏តាំងប្រែទៅ ៗ កាលដើមជាកលលរូប ហើយប្រែទៅជា អព្ពុទ ជាបេសិ ជាឃន ចេះតែប្រែទៅ ៗ ដរាបដល់មរណភាពជាទីបំផុត នឹងរកទៀងរកប្រាកដមិនមាន ប្រៀបដូចពពកដែលតាំងឡើងហើយ ក៏ដល់នូវការអណ្ដែតឃ្លាតទៅ ៗ ដរាបដល់សូន្យបាត់ ។

មានពាក្យដីកាចារ្យវិសជ្ជនាថា ដែលមានព្រះពុទ្ធភាសិតថា សត្វដែលតាំងបដិសន្ធិ ក្នុងវេលារាត្រីយប់នោះ គឺថាដោយ យេភុយ្យន័យ ថាធម្មតាសត្វដែលកាន់យកបដិសន្ធិ ក្នុងវេលាយប់នេះមានដោយច្រើន ដែលនឹងកាន់យកបដិសន្ធិក្នុងវេលាកណ្ដាលថ្ងៃនោះមានដោយតិច ហេតុដូច្នោះអ្នកប្រាជ្ញគប្បីចូលចិត្តថា តើសត្វនោះព្រះអង្គសម្ដែងដោយ យេភុយ្យន័យ ឯអាយុនៃសត្វដែលកន្លងទៅ ៗ ដោយន័យដូចពណ៌នាមក

ដូច្នេះ ហេតុនេះព្រះអដ្ឋកថាលោកឧបមាទុកថា ជីវិតដែលអស់ទៅតិចទៅនោះ ដូចអាការដែលអស់ទៅនៃទឹកក្នុងស្នឹងតិចទៅ ៗ រឿយ ៗ ដោយអំណាចកំដៅនៃព្រះអាទិត្យ ក្នុងគិម្ហរដូវដែលដល់នូវសភាវហួតរីងអស់ទៅគ្រប់ថ្ងៃគ្រប់វេលា ពុំនោះសោតដូចផ្លែឈើ ដែលអាបោធាតុមិនបានជ្រាបដល់ នឹងជ្រុះចាកដើមក្នុងវេលាព្រឹក ក៏ធម្មតាផ្លែឈើដែលមានរស មានពណ៌ផ្សេង ៗ អាស្រ័យនឹងរសផែនដី ដែលទទឹកសើមជ្រាបឡើងទៅក្នុងដើម ទើបដល់នូវវឌ្ឍនាការចម្រើនទៅជាយ៉ាងល្អ បានជាបើរសផែនដីមិនអាចសើមជ្រាបឡើងទៅក្នុងដើមបាន ផ្លែឈើទាំងនោះ ក៏នឹងដល់នូវសេចក្ដីវិនាសចាកដើមមិនខាន សេចក្ដីនេះមានឧបមាដូចម្ដេចមិញ ជាឧបមេយ្យដូចជីវិតសត្វទាំងពួងនេះ អាស្រ័យនូវរសនៃអាហារដែលសើមជ្រាបទៅក្នុងកាយ ថាបើរសអាហារ មិនអាចជ្រាបទៅបានទេ ក៏នឹងដល់នូវសេចក្ដីហួតរីងដាច់ ជីវិតិន្ទ្រិយទៅមិនខាន យ៉ាងនោះ ក៏ឯរូបនិងនាមទាំងពួងនេះកាលបើជរា ព្យាធិ មរណ បៀតបៀនហើយ ក៏ដល់នូវសេចក្ដីគ្រាំគ្រា ស្វិតស្រពោនឈឺចាប់លំបាកវេទនា មានខ្យល់អស្សាសបស្សាសដាច់សូន្យទៅ សល់នៅតែពងកាយម្យ៉ាង ជាអសុកសាធារណលើផែនដីដូចគ្នា ប្រៀបដូចកាដនដីដែលបុគ្គលប្រហារដោយដំបង នឹងបែកធ្លាយខ្ចាត់ខ្ចាយទៅដូច្នោះឯង ហេតុដូច្នោះ ព្រះសម្មាសម្ពុទ្ធទ្រង់ភាសិត នូវព្រះគាថាយ៉ាងនេះទុកមក ។

អច្ចយន្តិអហោរត្តា ជីវិតំឧបរុជ្ឈតិ អាយុខីយតិ មច្ចានំ កុន្នទីនំវឧទកំ ផលានមិវបក្កានំ ចាតោ-បត្តនតោភយំ ឯវំជាតានមច្ចានំ និច្ចំមរណតោភយំ យំថាហិកុម្ភការស្ស កតំមត្តិកាភាជនំ ខុទ្ទកញ្ច មហន្តញ្ច យំបក្កំយញ្ចអាមកំ សព្វំភេទបរិយន្តំ ឯវំ-មច្ចានជីវិតំ ឧស្សាវោវតិណគ្គម្ហិ សុរិយស្សុគ្គមនំបតិ ឯវំអាយុមនុស្សានំមាមំអម្មនិវារយាតិ ។

សេចក្តីថា ថ្ងៃនឹងយប់ទាំងឡាយប្រព្រឹត្តកន្លងទៅយ៉ាងណា ជីវិតសង្ខារនៃសត្វទាំងឡាយ ក៏រមែងតែរលត់បាត់ទៅ ៗ យ៉ាងនោះឯង ទឹកក្នុងស្ទឹងដែលតែងរីងហួតទៅយ៉ាងណា អាយុសង្ខារនៃសត្វទាំងឡាយ ក៏តែងអស់ទៅជាធម្មតាយ៉ាងនោះ ភ័យរបស់ផ្លែឈើទុំទាំងឡាយ កើតឡើងអំពីកិរិយាជ្រុះចុះចាកដើមយ៉ាងណា ភ័យនៃសត្វទាំងឡាយកើតឡើងអំពីសេចក្តីស្លាប់ជានិច្ចយ៉ាងនោះ ភាជនដីឯណាតូច ឬ ធំ ចាស់ ឬ ថ្មី ដែលស្មូនឆ្នាំងធ្វើហើយ ហេតុដោយភាជនទាំងនោះ នឹងដល់នូវកិរិយាបែកធ្លាយជាបំណែកជាទីបំផុតយ៉ាងណា ជីវិតសង្ខារនៃសត្វទាំងឡាយក៏នឹងអន្តរាយទៅយ៉ាងនោះ ទឹកសន្សើមដែលជិតជាប់នៅចុងស្មៅហើយហួតរីងបាត់ទៅ ព្រោះអាស្រ័យនូវកំដៅនៃព្រះអាទិត្យយ៉ាងណា អាយុសង្ខារ

របស់មនុស្សសត្វទាំងឡាយ ក៏អស់ទៅយ៉ាងនោះឯង ហាក់ដូចជាទឹង ពោលអង្វរមកវិញថាម្នាលអ្នក ៗ កុំឃាត់ខ្ញុំឡើយ ឯវិវេចកាបច្ចុប្ប-ដ្ឋានតោមរណានុស្សតិតាំ ព្រះយោគាវចរ ដែលចម្រើននូវមរណានុស្សតិកម្មដ្ឋាននោះ គប្បីរលឹកនូវសេចក្ដីស្លាប់ ដោយវធក-បច្ចុប្បដ្ឋានដូចន័យដែលពោលមកនេះ ៗ

២- សម្បត្តិវិបត្តិ គឺឲ្យព្រះយោគាវចររលឹកនូវសេចក្ដីស្លាប់ដោយការបរិបូណ៌និងវិនាស គឺឲ្យរលឹកឃើញថាសត្វទាំងពួង ដែលកើតមកនេះបរិបូណ៌ហើយមានសេចក្ដីវិនាសទៅវិញ ដែលទឹងល្អទឹងចម្រើនទៅនោះកាលដែលវិបត្តិមិនទាន់មកដល់គ្របសង្កត់នៅឡើយ បើវិបត្តិមកដល់គ្របសង្កត់ហើយ ទឹងវិនាសឃ្លាតចាកវត្ថុគ្រប់ប្រការ សេចក្ដីល្អទឹងចម្រើនក៏បាត់ទៅ សេចក្ដីទុក្ខអាក្រក់ទឹងចូលមក កាយនិងចិត្តដែលធ្លាប់ជាសុខហើយក៏ត្រឡប់ជាទុក្ខវិញ មិនធ្លាប់សោយសោកហើយក៏ត្រឡប់ជាសោយសោកវិញ ដូចយ៉ាងព្រះបាទធម្មាសោករាជ ស្ដេចមានបុញ្ញានុភាពសោយរាជសម្បត្តិព្រមព្រៀងដោយសេចក្ដីសុខ ដល់នូវឥស្សរិយភាពជាធំក្នុងភូមិមណ្ឌលជម្ពូទ្វីប ស្ដេចបានបរិច្ចាគទានក្នុងពុទ្ធសាសនា អស់ព្រះរាជ-ទ្រព្យ ១០០ កោដិ មានអាណាចក្រផ្សាយទៅខាងក្រោមផែនដី ១យោជន៍ ខាងលើអាកាស ១យោជន៍ ប្រកបដោយសិរីសម្បត្តិសុខយ៉ាងនោះ កាលដែលមរណមកដល់ ក៏មានសេចក្ដីសោកកើតឡើងចំពោះព្រះអង្គ ហើយ

មានព្រះភក្ត្រាបែរស្ទុះទៅកាន់សេចក្ដីស្លាប់មិនត្រឡប់ក្រោយឡើយ ន័យ ១ ទៀតថា សព្វំអារោគ្យំព្យាធិបរិយោសានំ សព្វំយោព្វនំ ជរាបរិយោសានំ សព្វំជីវិតំមរណបរិយោសានំ សេចក្ដីថា ការនៃបុគ្គលមិនមានរោគគ្រប់ប្រការ គង់តែមានព្យាធិនៅបន្ទាប់ខាងមុខ កិរិយាដែលចម្រើនដោយវ័យទាំងពួង គង់តែមានជរានៅបន្ទាប់ខាងមុខ សេចក្ដីរស់នៅរាល់ថ្ងៃនេះ គង់តែមានមរណ នៅបន្ទាប់ខាងមុខ

សព្វោយោលោកសន្និវាសោ ជាតិយាអនុគតោ ជរាយអនុសតោ ព្យាធិនាអភិភូតោ មរណេនអព្ភាហតោ សេចក្ដីថា សត្វទាំងពួងដែលអាស្រ័យនៅក្នុងលោកទាំងអស់ តែងមានជាតិទុក្ខប្រដិតតាមលួងលោមធ្វើឲ្យវង្វេងភ្លាត់ស្មារតី ជរាទុក្ខតែងបង្រួតតែឲ្យដល់នូវវិបត្តិផ្សេង ៗ ព្យាធិទុក្ខជាអ្នកតាមញាំញី បៀតបៀនឲ្យឈឺចាប់សព្វាង្គកាយ មរណទុក្ខជាអ្នកគ្របសង្កត់បំបែកទម្លាយផ្ដាច់ផ្ដិលជីវិតិន្ទ្រិយឲ្យវិនាសសាបសូន្យទៅ ហេតុនេះទើបព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងថា ៖

យថាបិ សេលា វិបុលា នភំ អាហច្ចបព្វតា សមន្តា
អនុបរិយេយ្យុំ និប្ពោថេន្តា ចតុទ្ទិសា ឯវំជរាចមច្ចុច
អធិវត្តន្តិ បាណិនោ ខត្តិយេ ព្រាហ្មណេ វេស្សេ សុទ្ទេ
ចណ្ឌាលបុក្កុសេ នកិញ្ចិ បរិវជ្ជេតិ សព្វមេវាភិមទ្ទតិ
នតត្ថហត្ថីនំភូមិ នរថានំនបត្តិយា នចាបិមន្តយុទ្ធេន

សញ្ញាដេតុំដងេឆេភតិ ។

សេចក្ដីថា ជរក្ដី មច្ចុក្ដី នឹងបានវៀរលែងនូវបុគ្គលណា ១ មិនមានឡើយ តែងគ្របសង្កត់ញាំញីសព្វសត្វទាំងពួងទូទៅ គ្រប់រូបគ្រប់នាម មិនមានលើកទុកថាក្សត្រិយ៍ ថាព្រាហ្មណ៍ថាអ្នកឈ្មួញ អ្នកគ្រូ អ្នកបណ្ដាលអ្នកចោលនូវអាចម៍ សេចក្ដីមរណនេះ ឧបមាដូចភ្នំដែលមានដុំឬគាន់តែ ១ ធ្លាក់ចុះមកអំពីអាកាស ហើយវិលទៅជុំវិញក្នុងទិសទាំង ៤ សង្កត់សង្កិននូវវត្ថុទាំងពួង មិនមានវៀរទុកនូវសត្វ ទីង សង្ខារណា ១ ឡើយ បើនឹងតយុទ្ធដោយស្ដេចមច្ចុរាជនោះ មិនមែនជាវិស័យតយុទ្ធបាន ព្រោះហេតុនោះថាក្នុងមរណសង្គ្រាមនោះ មិនមានទីតាំងនៃពលដំរី ពលសេះ ពលរថ ពលថ្មើរជើង មិនមានទីតាំងដោយគួរតែងទ្វារទាំងពួង ដែលនឹងមានពលពាហនច្រើន ក៏មិនត្រូវការនឹងយកមកតយុទ្ធដោយមរណសង្គ្រាមនោះ មិនអាចនឹងយកមកតតាំងបានឡើយ ទោះបីនឹងឲ្យនូវមាសប្រាក់កែវមណីប៉ុន្មាន ៗ ក្ដី ឬបេះមន្តអាគមយ៉ាងណា ៗ ក្ដី ក៏មិនអាចនឹងយកមកតយុទ្ធដោយស្ដេចមច្ចុរាជនោះបានឡើយ តំរវត្ថុ-បេក្ខជសម្បត្តិ វិបត្តិតាមរណំអនុស្សរិតព្វំ ព្រះយោគាវចរគាលកំណត់នូវសេចក្ដីស្លាប់ដូច្នោះហើយ គប្បីរលឹកដល់មរណដោយសម្បត្តិវិបត្តិដូចន័យដែលបានពោលមកហើយនេះចុះ ។

៣- ឧបសំហរណតោ គឺឲ្យព្រះយោគាវចររលឹកដល់សេចក្ដី

ស្លាប់ដោយ ឧបសំហារណា គឺថាឲ្យរើកដល់សេចក្ដីស្លាប់នៃបុគ្គល ដទៃ ហើយនាំចូលមកទុកដាក់ក្នុងខ្លួន កាលដែលនឹងរើកនោះ គប្បី រើកដោយអាការ ៧ ប្រការគឺ ៖

ក- យសមហត្តតោ ឲ្យរើកដោយការច្រើនទៅដោយយស គឺថាឲ្យរើកថាស្ដេចមច្ចុរាជនេះ នឹងបានគោតក្រែងថាអ្នកនេះ ជាមនុស្ស មានបរិវារច្រើនកុំបៀតបៀនឡើយ នឹងបានគោតក្រែងដូច្នេះមិនមានអំពាល យ៉ាងស្ដេចធំទាំងឡាយមានមហាសម្មតិរាជ និង មន្ធាតុរាជ និង មហា-សុទស្សនចក្រពត្រាធិរាជ ដែលមានឥស្សរិយយស និង បរិវារយសជាយ៉ាង ច្រើន បរិបូណ៌ទៅដោយពលពាហន និង ទ្រព្យសម្បត្តិ ជានុឡារិកភាព នោះ ក៏គង់លុះក្នុងអំណាចស្ដេចមច្ចុរាជទាំងអស់ នឹង ចាំពោលទៅថ្វីដល់ ខ្លួនអាត្មានេះ នឹងផុតចាកអំណាចស្ដេចមច្ចុរាជឯណាបាន ឯវិធីយសមហ-ហត្តតោអនុស្សរិតនេះ ព្រោះយោគាវចរគប្បីរើកដោយការច្រើនទៅ ដោយយសដូចពោលមកនេះ ។

ខ.បុញ្ញមហត្តតោ ឲ្យរើកដោយការច្រើនទៅដោយបុណ្យ គឺថាឲ្យរើកដល់អ្នកមានបុណ្យទាំងឡាយ មានជោតិកសេដ្ឋី និងជដិល សេដ្ឋី និងឧគ្គសេដ្ឋី និងមេណ្ឌកសេដ្ឋី និងបុណ្ណកសេដ្ឋីជាដើម បណ្ដាជន ដែលមានបុញ្ញាតិសម្ភារទាំងនោះ ជោតិកសេដ្ឋីនោះ មានប្រាង្គណ៍ប្រា-សាទហើយទៅដោយកែវ ៧ ប្រការ មានថ្ម ៧ ជាន់ កំពែង ៧ ជាន់សុទ្ធតែ

ហើយទៅដោយកែវ ៧ ប្រការ ហើយមានទាំងដើមកល្បព្រឹក្សកើតឡើង ក្នុងជ្រុងទាំង ៤ នៃប្រាសាទ កំណាប់ ១ មានទំហំមាត់ជាង ១ យោជន៍ ១ ទៀតមានទំហំមាត់ កន្លះយោជន៍ ១ ទៀតមានមាត់ជាង ៣០០ សិន ១ ទៀតមានមាត់ជាង ១០០ សិន ហើយមានស្រីកែវ មកអំពីឧត្តរកុរុទ្វីប ជាអគ្គកិរិយា ឯជដិលសេដ្ឋីនោះទៀត មានភ្នំមាសកើតឡើងខាងក្រោយផ្ទះ និងកាយកើបជញ្ជូនយកប៉ុន្មាន ៗ ក៏មិនអស់មិនមានរលោះឡើយ មេណ្ឌកសេដ្ឋីនោះ មានពពែមាសកើតឡើងដោយបុណ្យពេញទៅក្នុងទីប្រមាណ ៨ ករីស ក្នុងពោះពពែនោះពេញទៅដោយវត្ថុទាំងពួង បើនឹងប្រាថ្នាវត្ថុឯណា ៗ ក៏ដកយកតែឆ្នុកដែលបិទមាត់ពពែនោះចេញ ហើយវត្ថុនោះ ៗ ក៏ហូរចេញចាកមាត់ពពែនោះមក បានសម្រេចដូចសេចក្តីប្រាថ្នា បុណ្ណកសេដ្ឋីនោះ កាលដើមចេញទៅភ្ជួរស្រែ អាចម៍បំណះក៏ត្រឡប់ទៅជាមាស លុះបានធ្វើជាសេដ្ឋីហើយ ទីភូមិធ្វើផ្ទះនៅនោះ ក៏មានកំណប់ទ្រព្យពេញក្នុងទីនោះ អ្នកមានបុញ្ញាភិសម្ភារច្រើនផ្សេង ៗ គ្នាប្លែកវិសេសពីគ្នា ជនទាំងឡាយដទៃគេតែងពុល្យ ថាជាអ្នកមានបុញ្ញានុភាពប្រាកដក្នុងលោកនេះ ក៏អ្នកទាំងអំបាលនោះ អ្នកណា ១ មិនអាចយកទ្រព្យទាំងនោះ មកជាថ្នូរដូរខ្លួន លោះខ្លួនឲ្យផុតចាកអំណាចនៃស្តេចមច្ចុរាជនោះបាន សុទ្ធតែដល់នូវមរណភាព បែកធ្លាយខន្ធបាត់ទៅទាំងអស់ នឹងបាច់ពោលទៅថ្វីដល់បុគ្គលប្រាកដដូចជាអាត្មានេះឯង ធ្វើម្តេចនឹងរួចចាកមរណភាពទៅបាន ឃរំបុញ្ញមហាក្សត្រ អនុស្សរិតពុំ

ព្រះយោគាវចរគប្បីរលឹកដោយការច្រើន ទៅដោយបុណ្យយ៉ាងនេះ ។

គ.ថាមមហគ្គតោ ឲ្យរលឹកដោយការច្រើនទៅដោយកម្លាំង គឺថាឲ្យរលឹកដល់បុគ្គលដែលមានកម្លាំងច្រើន ប្រាកដយ៉ាងអ្នកចម្បាប់ឈ្មោះ វាសុទេព ពលទេព ភិមសេន យុធិដ្ឋិល ហនុរជាដើម បណ្ដាអ្នកទាំងឡាយនេះ ជនម្នាក់ ៗ នោះសឹងមានកម្លាំងច្រើន ។ កម្លាំងនាយខ្មាន់ធ្នូ ៥០០ នាក់ ទើបស្មើនឹងកម្លាំងនាយភិមសេនតែម្នាក់ ក៏បុគ្គលដែលមានកម្លាំងច្រើន ដែលគេល្បីប្រាកដក្នុងលោកនេះ ម្ដេចក៏មិនអាចតយុទ្ធដោយស្ដេចមច្ចុរាជបាន ចំណង់បើខ្លួនអាត្មានេះ នឹងអាចតយុទ្ធឯណាបានភ័យ ឯវំថាមមហគ្គតោអនុស្សរិតព្វំ ព្រះយោគាវចរគប្បីរលឹកដោយការច្រើនទៅដោយកម្លាំង ដូចពោលមកហើយយ៉ាងនេះ។

ឃ. ឥទ្ធិមហគ្គតោ ឲ្យរលឹកដោយការច្រើនទៅដោយឫទ្ធិ គឺថាឲ្យរលឹកដល់បុគ្គលកើតមកក្នុងលោកនេ ដែលមានឫទ្ធិសក្ដានុភាពច្រើនដោយប្រការឯណា ៗ ក្ដី ក៏មិនអាចនឹងធ្វើនូវសង្គ្រាមតនឹងស្ដេចមច្ចុរាជនោះបានរម្យាល ដូចព្រះមហាមោគ្គល្លានត្ថេរ ជាទុតិយសាវកនៃព្រះសម្មា-សម្ពុទ្ធជាម្ចាស់ ប្រកបដោយឥទ្ធានុភាព ដ៏លើសជាទីឯតទគ្គ បំណែកខាងឫទ្ធិបណ្ដាសាវ័កក្នុងសាសនានេះ សាវ័កណា ១ នឹងមានឫទ្ធិដូចព្រះមហាមោគ្គល្លាននេះមិនមាន ព្រះមហាមោគ្គល្លាននេះ អាចញុំាងវេជយន្តប្រាសាទ របស់ទេវរាជ ឲ្យកម្រើកញាប់ញ័រដោយម្រាមមេជើងទៅបាន

ឯកិច្ចដែលនឹងចូលឈានសមាបត្តិឲ្យយ៉ាងឆាប់ មិនមានបុគ្គលឯណាស្មើ មានឫទ្ធិដល់ត្រឹមនេះហើយ ម្តេចក៏គង់ចូលទៅកាន់មាត់នៃមច្ចុរាជ ព្រមទាំងឫទ្ធិ ទាំងតេជៈអំណាច ប្រៀបដូចសត្វម្រឹគដែលចូលទៅកាន់មាត់នៃក្រសររាជសីហ៍ ក៏យ៉ាងខ្លួនអាត្មានេះ ធ្វើម្តេចហើយនឹងផុតអំណាចនៃស្តេចមច្ចុរាជនោះបាន ឯវំឥទ្ធិមហន្តតោ អនុស្សរិតុំ ព្រះយោគាវចរគប្បីរលឹកដោយការច្រើនទៅដោយឫទ្ធិដូចពោលមកនេះ ។

៥- បញ្ញាមហន្តតោ ឲ្យរលឹកដោយការច្រើនទៅដោយបញ្ញា គឺថាឲ្យរលឹកឃើញថា បណ្តាសត្វទាំងឡាយដែលវិលវល់ នៅក្នុងផលា-លោកនុយសាគរនេះ សត្វណា ១ ដែលមានបញ្ញាឆ្លៀវឆ្លាសយ៉ាងណា ៗ ក៏គង់មិនអាចគិតរកលេសឧបាយ គេចឲ្យផុតចាកអំណាចនៃស្តេចមច្ចុរាជនោះបាន កុំបាច់និយាយឡើយដល់សត្វដទៃ ៗ ដែលមានបញ្ញាបារមីតិច ទោះបើលោកមានបញ្ញាបារមីមុតក្លា ប្រាកដយ៉ាងព្រះមហាសារី-បុត្តត្ថេរ ជាបឋមសាវ័ក ប្រកបដោយបញ្ញាដ៏ក្លាហាន បំណែកគ្រាប់ភ្លៀងធ្លាក់ចុះក្នុងវែងចក្រវាឡ ធ្លាក់ចុះយូរប្រមាណ ១ កល្ប ដំណក់គ្រាប់ភ្លៀងនិងល្អងគ្រាប់ភ្លៀងនោះ មានច្រើនតិចប៉ុន្មាន ៗ ព្រះសារីបុត្តលោកអាចរាប់បានទាំងអស់ បណ្តាសត្វក្នុងលោកនេះ លើកទុកតែព្រះសម្មាសម្ពុទ្ធជាម្ចាស់ចេញ ក្រៅពីនោះហើយអ្នកណា ១ ឡើយក៏នឹងមានបញ្ញាច្រើនដូចព្រះសារីបុត្តនោះគ្មាន បញ្ញាព្រះសារីបុត្តនោះថា បើចែក

ចេញជា ១៦ ៗ ហើយលើក ១៥ ចេញ យកតែចំណែក ១ ចំណែក ១ នោះមកចែកចេញជា ១៦ ហើយលើកចេញ ១៥ ចំណែកទៀត យកតែចំណែក ១ ខាងចុងបំផុតនោះមកចែកចេញជា ១៦ ចំណែកទៀតតាមន័យដូច្នេះដល់ទៅ ១៦ ដង ហើយទើបយកបញ្ញាព្រះសារីបុត្តត្ថេរ ១ ចំណិតដែលចែកជា ១៦ ចំណែកក្នុងទីបំផុតនោះ មកប្រៀបដោយបញ្ញាបណ្ឌិតជាតិទាំងពួងៗ ក៏តិចជាងបញ្ញាព្រះសារីបុត្តត្ថេរ ១ ចំណែកដែលជាបំផុតនោះទៀត ព្រះសារីបុត្តនេះបានជាទីឯកទគ្គ ចំណែកខាងបញ្ញាច្រើនបណ្ដាលោកដែលមានបញ្ញាច្រើន ដល់ទីបំផុតយ៉ាងនេះហើយ ក៏គង់មិនអាចនឹងកន្លងបង់នូវអំណាចនៃស្ដេចមច្ចុរាជនោះបាន យ៉ាងខ្លួនអាត្មានេះនឹងអាចកន្លងនូវអំណាចនៃស្ដេចមច្ចុរាជនោះឯណាបាន ឃើញបញ្ញាមហាត្តតោ អនុស្សរិតព្វំ ព្រះយោគាវចរ គប្បីរលឹកដោយការច្រើនទៅដោយបញ្ញា ដូចន័យដែលពោលមកហើយនេះ ។

ចៈ បច្ចេកពុទ្ធតោ ឲ្យរលឹកដោយព្រះបច្ចេកពុទ្ធគឺឲ្យរព្ញុកថា ព្រះបច្ចេកពុទ្ធទាំងពួងនោះ ប្រកបដោយបញ្ញាពលនិងវីរិយពលបានកាប់កិនញាំញីនូវសឹកសត្រូវគឺកិលេសធម៌ទាំងពួង ហើយដល់នូវបច្ចេកពោធិ-ញាណ ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយខ្លួនឯង មិនមានគ្រូអាចារ្យប្រៀនប្រដៅឡើយ ក៏ព្រះបច្ចេកពុទ្ធប្រសើរដោយគុណយ៉ាងនេះហើយ ម្ដេចក៏គង់មិនផុតចាកអំណាចនៃស្ដេចមច្ចុរាជនោះបាន ចំណង់

បើយ៉ាងអាត្មានេះនឹងអាចរួចផុតមកអំពីទីណា ឯវំបច្ចេកពុទ្ធោ អនុស្សរិតព្វំ ព្រះយោគាវចរគប្បីរលឹកដោយព្រះបច្ចេកពុទ្ធ ដូចន័យយ៉ាងនេះ ។

៥. សម្មាសម្ពុទ្ធោ ឲ្យរលឹកដោយព្រះសម្មាសម្ពុទ្ធ គឺឲ្យរលឹកថា ព្រះសម្មាសម្ពុទ្ធ ព្រះអង្គមានព្រះរូប ព្រះឆោម ព្រះសរីរកាយដ៏វិចិត្រទៅ ដោយទ្វត្តឹសមហាបុរិសលក្ខណ គឺលក្ខណសម្រាប់មហាបុរសទាំង ៣២ និងអសីត្យានុព្យញ្ជនទាំង ៨០ គត់ ប្រសើរដោយធម្មកាយ បរិបូណ៌ដោយគែរពោលគឺ សីលខន្ធ សមាធិខន្ធ បញ្ញាខន្ធ វិមុត្តិខន្ធ វិមុត្តិញាណទស្សនខន្ធ និងបរិសុទ្ធ ដោយអាការទាំងពួង ជាបុគ្គលដល់ហើយនូវការច្រើនទៅដោយយស ដោយបុណ្យ ដោយកម្លាំង ដោយឫទ្ធិ ដោយបញ្ញា និងគេបុគ្គលឯណា ១ ប្រៀបផ្ទឹមជាគូស្មើមិនបាន អហំសម្មាសម្ពុទ្ធោ សោបិសសីលវុឌ្ឍិឆាតេជ មហាអគ្គិក្ខន្ធោរិយ ព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គបានកាប់បំបាក់នូវកាំកង់នៃសំសារចក្ក ត្រាស់ដឹងនូវធម៌ទាំងពួងដោយព្រះអង្គឯង ដោយអាការមិនបានវិបរិត ព្រះអង្គមានគុណប្រសើរយ៉ាងនេះហើយ ម្តេចឡើយក៏គង់ទ្រង់រម្ងាប់នូវសំខារធម៌ទាំងពួងចូលទៅកាន់ព្រះនិព្វាន ជាស្ថានសូន្យចាករាគាទិកិលេសដោយទឹកភ្លៀងគឺមរណ ព្រះអង្គប្រៀបដូចជាគំនរភ្លើងធំ ដែលជាប្រទីបពន្លឺកងត្រៃភព រលមរលត់សូន្យទៅដោយអំណាចទឹក

ភៀង ប្រឡែកល្បលាយបាត់សន្ធាររកបញ្ញត្តិមិនមាន ។

ឃរំមហានុភាវស្ស យញ្ញាមេតំមហោសិថោ ឧក-

យេឧឧលដ្ឋាយ មរណាំសមាគតំ ធិលដ្ឋំ វីតសារដ្ឋំសព្វ

សត្តាភិមទ្ទនំតយិទំមាធិសំសត្តំ តាជំណាភិកវស្សតិ ។

សេចក្ដីថា ព្រះសម្មាសម្ពុទ្ធព្រះអង្គជាអ្នកស្វែងរកនូវគុណមានសីល

គុណជាដើមនេះមានអានុភាពច្រើនយ៉ាងនេះ ម្ដេចក៏គង់សេចក្ដីមរណមិន

មានកោតខ្លាច មិនមានអៀនខ្មាសសោះ ក៏ឯមរណនេះ ជាសង្គ្រាម

ធំក្នុងដណ្ដើមលោកតែងញាំញីនូវសត្វទាំងពួង ទាំងឡាយ ដែលមិនមាន

ខ្មាស មិនមានញញើត និងគ្របសង្កត់នូវសត្វប្រាកដ ដូចយ៉ាងអាត្មា

នេះផងមិនខាន ឃរំសម្មាសម្ពុទ្ធគោអនុស្សរិតព្វំ ព្រះយោគា-

វចរគប្បីរលឹកដោយព្រះសម្មាសម្ពុទ្ធដូចន័យយ៉ាងនេះ ។

ឯអាការទាំង ៧ ប្រការនោះ រួមចូលគ្នាជាបទ ១ ហៅថា

ឧបសំហារណា ។

៤- កាយពហុសាធារណតោ ឲ្យព្រះយោគាវចររលឹកថា

អយំកាយោពហុសាធារណោ អសីតិយាតាវគាិមិកុ-

លានំសាធារណោ សេចក្ដីថារូបកាយនៃសត្វទាំងពួងរស់សាធារណ

ទួទៅ ដល់ពួកដង្កូវទាំងឡាយ ៨០ ត្រកូល ដង្កូវដែលអាស្រ័យនូវស្បែក

សម្បុរថ្ងៃ ក៏ទំពាស៊ីនូវស្បែកសម្បុរថ្ងៃដែលអាស្រ័យនៅក្នុងស្បែកបន្ទាប់

សាច់ ក៏ទំពាស៊ីនូវស្បែកបន្ទាប់សាច់ ដែលអាស្រ័យនៅក្នុងសាច់ ក៏ទំពាស៊ីសាច់ ដែលអាស្រ័យនូវសសៃ ក៏ទំពាស៊ីសសៃ ដែលអាស្រ័យនូវឆ្អឹង ក៏ទំពាស៊ីឆ្អឹង ដែលអាស្រ័យនូវខួរក្នុងឆ្អឹង ក៏ទំពាស៊ីនូវខួរក្នុងឆ្អឹង ជាយត្ថិ ជិយ្យត្ថិ មិយ្យត្ថិ ដង្កូវទាំងឡាយនោះ កើតក្នុងកាយ ចាស់ក្នុងកាយ ស្លាប់ក្នុងកាយ បន្ទោបង់នូវឧច្ចារបស្សាវៈក្នុងកាយ ។

កាយោ រេនសំ សុគិយំ ចេរ កិលាឯនភាលាឯសុ
សានំ វត្ថកុឌិឯបស្សានោណិកា ។

កាយនៃយើងទាំងពួងនេះ ជាផ្ទះសម្រាប់ប្រសូតិនៃសត្វដង្កូវ ជារោងសម្រាប់ដាក់សត្វដង្កូវឈឺ ជាព្រៃសមសាន សម្រាប់ចោលសាកអសុភដង្កូវ ជាបង្គន់ ជាស្នូកសម្រាប់ផ្ទុះបុ្ភថាសម្រាប់បន្ទោបង់នូវឧច្ចារបស្សាវៈនៃដង្កូវ គួរតែសង្វេគវេទនាកាយនៃយើងគេទាំងឡាយនេះ ដូនកាលដង្កូវកម្រើកជ្រួលជ្រើមឡើង ហើយក៏ដល់នូវសេចក្ដីស្លាប់ ដោយដង្កូវកម្រើកនោះក៏មាន ខាងក្នុងក្រៅកាយនេះ នឹងមានតែពួកដង្កូវបៀតបៀនតែម្យ៉ាងក៏ទេ សឹងមានពេគច្រើនជាងរយដំពូក បៀតបៀនក្នុងកាយនេះទៀត ហើយក៏ជាទីសាធារណនូវទៅដល់សត្រូវទាំងឡាយខាងក្រៅមានសត្វពស់ និងខ្លួយជាដើម ជាបច្ច័យនៃសេចក្ដីស្លាប់ពងកាយនេះជាទីមុត ត្រូវអំពីឧបទ្ទវន្តរាយទាំងពួងផ្សេងៗឧបមាដូចបន្ទោងដែលបុគ្គលភ្ជោងទុកក្នុងទីប្រជុំផ្លូវធំទាំង ៤ ជាទីត្រូវគ្រាន់នៃសរ និងលំពែងធំ និងដុំថ្មជាដើម

ហេតុនេះព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងទុកថា ៗ

ឥជកិច្ចកិច្ចុនិសេធិច្ចេ រត្តិយាបតិហិតាយ

ឥតិបដិសញ្ចិក្ខតិ ៗ

សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានមរណសតិក្នុងសន្តាន កាលបើពេលាថ្ងៃប្រព្រឹត្តកន្លងទៅហើយ រាត្រីនឹងចូលមក គប្បីពិចារណា ដល់មរណភាពនៃអាត្មាថា ហេតុដែលនឹងឲ្យអាត្មាដល់នូវសេចក្តីអន្តរាយ ជាបច្ច័យនៃសេចក្តីស្លាប់នោះច្រើនយ៉ាងណាស់ ដូចកាលពស់ចឹក ខ្យាដំរីចឹក ក្អែបខាំក៏មាន ដូចកាលអាហារដែលបរិភោគចូលទៅហើយមិនទ្រុឌទ្រោម ប្រមាត់កម្រើក ស្លេសកម្រើក ខ្យល់មានមុខដ៏មុតដូចកាំបិតចាប់ចុកក៏មាន ហេតុទាំងនេះក៏សុទ្ធតែសេចក្តីអន្តរាយ ជាបច្ច័យនៃមរណទាំងអស់ ឯវំកាយពហុសាធារណតោ មរណំអនុស្សរិតព្វំ ព្រះយោគាវចរគប្បីពិចារណានូវសេចក្តីស្លាប់ ដោយកាយពហុសាធារណ យ៉ាងនេះ ៗ

៥-អាយុទុព្វលតោ ឲ្យព្រះយោគាវចររលឹកសេចក្តីស្លាប់ដោយ អាយុមានកម្លាំងថយ គឺឲ្យរលឹកឲ្យឃើញថា អាយុរបស់សត្វទាំងពួង រកកម្លាំងមិនមានជាទុព្វលភាពពេកណាស់ ដូចបទថា ៖

សត្តានំជីវិតំអស្សាសបស្សាសូបនិពទ្ធំចេវ ឥរិយាបថូប

និពទ្ធំច សីតុណ្ហូបនិពទ្ធំច មហាភូតូបនិពទ្ធំច អាហារូបនិពទ្ធំច ។

សេចក្តីថា ជីវិតនៃសត្វទាំងឡាយនេះ ជាប់ចំពោះដោយដង្ហើមចេញនិងដង្ហើមចូលផង ថាបើដង្ហើមចេញចូលនោះ មិនបានប្រព្រឹត្តទៅហើយ ជីវិតក៏នឹងដាច់ទៅសូន្យទៅនឹង ដល់នូវសេចក្តីមរណភាពដោយពិត ជីវិតនេះជាប់ទៅដោយឥរិយាបថផង កាលបើឥរិយាបថទាំង ៤ ប្រព្រឹត្តទៅស្មើល្អ ជីវិតនោះក៏រស់នៅបានមិនរលត់ មិនសូន្យទៅ បើឥរិយាបថនោះប្រព្រឹត្តទៅមិនស្មើ គឺអង្គុយច្រើន ឬដេកច្រើន ឬឈរច្រើន ឬដើរច្រើនជ្រុលដោយឥរិយាបថណា ១ ហើយ ក៏ជាហេតុនឹងឲ្យអាយុនោះ តិចទៅ ជីវិតនេះជាប់ទៅដោយសេចក្តីក្តៅនិងត្រជាក់ផង កាលបើក្តៅនិងត្រជាក់នោះតាំងនៅស្មើល្អ ជីវិតក៏រស់នៅប្រព្រឹត្តទៅបាន បើក្តៅឬត្រជាក់នោះជ្រុលហួសប្រមាណហើយ អាយុក៏នឹងដាច់សូន្យទៅ ជីវិតនេះជាប់ទៅដោយមហាភូតរូប ៤ គឺធាតុទាំង ៤ កាលបើធាតុទាំង ៤ នោះប្រព្រឹត្តិទៅស្មើល្អ ជីវិតក៏ចម្រើននៅបាន បើធាតុទាំង៤ ធាតុណា ១ ប្រព្រឹត្តិទៅមិនស្មើកម្រើកហើយ អាយុនឹងដាច់សូន្យទៅ ទុកជាបុគ្គលបរិបូណ៌ដោយកម្លាំងច្រើនយ៉ាងណា ៗ ក្តី តែធាតុណា ១ កម្រើកហើយក៏គង់នឹងមានកាយនោះ គ្រាំគ្រាជារោគផ្សេង ៗ មានអតិសាររោគ គឺរោគចុះឈាមជាដើម មានកាយនោះពុកស្អុយសៅហ្មង ក្តៅក្រហាយក្រវល់ក្រវាយខ្លួនទៅសព្វាង្គកាយ ជួនកាលមានទឹកជាប់ឃ្លាតចេញពីគ្នា

កំដាច់ជីវិតិន្ទ្រិយសូន្យទៅ ជីវិតនេះជាប់ទៅដោយអាហារ កាលបើបាន អាហារបរិភោគចូលទៅ ជីវិតក៏ប្រព្រឹត្តទៅបាន ថាបើមិនបានបរិភោគ អាហារហើយ ឬបរិភោគឲ្យច្រើនកើនលើសប្រមាណ ភ្លើងធាតុនឹងអាច កំដៅឲ្យទ្រុឌទ្រោមទៅមិនបាន ហើយអាយុក៏នឹងដាច់សូន្យទៅ អាស្រ័យ ហេតុនេះឯងទើបសម្ដែងថា ជីវិតិន្ទ្រិយរបស់សត្វទាំងពួងនោះ ជាប់ទៅ ដោយអស្សាសបស្សាសផង ជាប់ទៅដោយសេចក្ដីក្ដៅ និង ត្រជាក់ផង ជាប់ទៅដោយមហាភូតរូបផង ជាប់ទៅដោយអាហារផង ឯវំ អាយុ ទុព្វលតោ មរណំ អនុស្សរិតព្វំ ព្រះយោគាវចរគប្បីរលឹកដល់ សេចក្ដីស្លាប់ ដោយអាយុទុព្វលដូចមានន័យដែលសម្ដែងមកនេះ ។

៦ អនិមិត្តតោ ឲ្យព្រះយោគាវចររលឹកសេចក្ដីស្លាប់ ដោយ កំណត់គ្មានថា ៖

ជីវិតំ ព្យាធិ កាលោ ច ទេហនិក្ខេបនំ គតិ បញ្ចេតេ
ជីវលោកស្មឹ អនិមិត្តា ន ញាយរេ ។

អធិប្បាយថា ហេតុដែលនឹងកំណត់មិនបានរបស់សត្វនោះមាន ៥ យ៉ាង គឺជីវិតកំណត់មិនបាន ១, សេចក្ដីឈឺចាប់កំណត់មិនបាន ១, កាលវេលានឹងស្លាប់កំណត់មិនបាន ១. ទីដែលនឹងចោលកឡេវរសាកអសុភ កំណត់មិនបាន១, ដំណើរដែលនឹងទៅកាន់គតខាងមុខទៀត កំណត់មិនបាន ១, រួមគ្នាត្រូវជា ៥ យ៉ាង អធិប្បាយថាសត្វទាំងឡាយនឹងកំណត់

ថា អញនឹងមានជីវិតប្រព្រឹត្តទៅបានដល់កាលត្រឹមនោះ ៗ បើមិនទាន់ដល់កាលត្រឹមនោះទេ អញនឹងមិនស្លាប់មុន លុះតែដល់កាលកំណត់នោះទើបស្លាប់ នឹងកំណត់យ៉ាងនេះមិនបាន កាល ល កា:ល បិសន្តាយរត្តិ សត្វទាំងឡាយដែលកើតឡើងក្នុងគភ៌មាតានោះ ទើបនឹងតាំងឡើងជាកលលរូបហើយវិនាសទៅក៏មាន ជាអព្វុទហើយក៏មាន ដួនកាលជាបេសិជាឃនហើយវិនាសទៅក៏មាន ដួនកាលបែកបញ្ចសាខាហើយវិនាសទៅក៏មាន ដួនកាលតាំងនៅបាន ១ ខែ ២ - ៣ - ៤ - ៥ - ១០ ខែ ហើយក៏វិនាសទៅក៏មាន សត្វជំពូកខ្លះ ស្លាប់ក្នុងកាលចេញចាកគភ៌មាតាក៏មាន សត្វខ្លះចេញចាកគភ៌មាតាហើយ តាំងនៅបាន ១ ថ្ងៃ ២ ថ្ងៃ ៣ ថ្ងៃ ហើយស្លាប់ទៅក៏មាន នៅបាន ៤-៥-១០ ថ្ងៃស្លាប់ទៅក៏មាន នៅបាន ១ ខែ ២ ខែ ៣ ខែ ហើយស្លាប់ទៅក៏មាន នៅបាន ៤-៥-១០ ខែ ហើយស្លាប់ទៅក៏មាន នៅបាន ១-២-៣ ឆ្នាំ ហើយស្លាប់ទៅក៏មាន តាំងនៅបាន ១០-២០-៣០ ឆ្នាំ ហើយស្លាប់ទៅក៏មាន ដែលនឹងកំណត់ជីវិតនេះកំណត់មិនបាន ឯសេចក្ដីឈឺចាប់នោះទៀតក៏កំណត់មិនបាន ដូចគ្នា ដូចបទថា ឥមិ ជាតា ព្យាធិ ជាសន្តា មរន្តិ អញ្ញេ ជ ថាសត្វទាំងឡាយនឹងស្លាប់ដោយជម្ងឺនេះ ដោយរោគឈ្មោះនេះ ៗ យ៉ាងនេះកំណត់មិនបាន សត្វជំពូកខ្លះស្លាប់ដោយចក្ខុរោគគឺរោគក្នុងភ្នែក ឬសោតរោគ គឺរោគក្នុងត្រចៀក ដួនកាលស្លាប់ដោយឃានរោគ គឺរោគក្នុងច្រមុះ ឬជិវ្ហារោគ គឺរោគក្នុងអណ្ដាត កាយរោគ គឺរោគក្នុងកាយ សីស

រោគ គឺរោគក្នុងក្បាលមានប្រការផ្សេង ៗ សត្វដំពូកខ្លះស្លាប់ដោយរោគដែលតាំងឡើងអំពីប្រមាត់ហៅថាបិតសមុដ្ឋានរោគ ខ្លះស្លាប់ដោយរោគដែលតាំងឡើងអំពីស្លេសហៅថាសេម្ហសមុដ្ឋានរោគយ៉ាងនេះ កាលវេលាដែលនឹងស្លាប់នោះទៀតក៏រកកំណត់មិនបានដូចគ្នា ដូចបទថា ឥមស្មឹ យេវកាលេ មរិតព្វំ អញ្ញស្មឹ ថាសត្វយ៉ាងនេះត្រូវស្លាប់ក្នុងពេលដូច្នេះ ក្រៅពីពេលនេះមិនស្លាប់ឡើយ នឹងកំណត់ដូច្នេះមិនបាន ដួនកាលសត្វខ្លះស្លាប់ក្នុងពេលព្រឹកក៏មាន សត្វខ្លះស្លាប់ក្នុងវេលាថ្ងៃត្រង់ ខ្លះស្លាប់ក្នុងវេលាថ្ងៃរសៀលក៏មាន ដួនកាលស្លាប់ក្នុងពេលបឋមយាម ឬ មជ្ឈិមយាម ឬ បច្ឆិមយាមក៏មាន ដែលនឹងកំណត់វេលាស្លាប់នោះកំណត់មិនបាន ដូចន័យដែលពោលមកនេះជាដើម ៗ

(មានតទៅទៀត)

អំពីដើមកំណើតប្រាសាទអង្គរ (តពីលេខ ៤)

លោកល្វីហ្វីណូត៍ អាចារ្យបង្រៀនឧត្តមវិជ្ជា សាលាកូឡេសដឺហ្វ្រង់ស្រ

នៅក្រុងប៉ារីសជាអ្នកអធិប្បាយ

ក្រុមការ ជុំ-ម៉ៅ

ធ្វើរាជការនៅព្រះរាជបណ្ណាល័យ ប្រែចេញជាភាសាខ្មែរ

(ចប់)

.បន្ទាយឆ្មារនៅជាខាងកើតបំផុតទីរួមខែត្របាត់ដំបង នៅលើដើងភ្នំដងរែក គឺជាប្រាសាទ ១ ដែលបាក់បែបអន្ធការជាងគេហើយប្រហែលជាទីក្រុងស្តេចដែលផុតត្រឹមប្រាសាទនេះ មោនសៀ គ្រោលីយេ .បានពិនិត្យសព្វគ្រប់ទៅឃើញថា ប្រាសាទនេះប្រហែលពិតជារបស់ស្តេចជ័យវរ្ម័នទី ៦ គឺប្រាសាទអគ្រេម្រន្ទបុរ ដែលសាងក្នុងសករាជ ៨០០ ក្នុងពាក់កណ្តាលឆ្នាំ ៩០០ នៃគ្រិស្តសករាជ ។

បើយើងពិនិត្យបន្ទាយឆ្មារតំពីខាងសាសនានោះនឹងស្គាល់បែបយ៉ាង១រំពេចនៅវេលាដែលក្រឡេកទៅចំ គឺជំបូលតាំងអស់នោះមានបន្តុបកំពូលរចនានៅខាងលើមុខពុទ្ធរូប ដែលទ្រង់ក្អែនក្នុងក្បាំង ដែលលកខូងគ្រប់តែសសរតាំងអស់នោះ មានរចនាជារូបស្រីទេពអប្សរ និងពុទ្ធរូបគ្រប់កន្លែង គេបានឃើញនៅមេក្លារខាងលើ រឿងរ៉ាវតាំងឡាយរបស់ព្រះពុទ្ធមានគ្រក់ចេញពីទតរនៅទ្រង់ផ្នួសប្តូគ្រង់គេគោរពព្រះពុទ្ធជាដើមនៅផ្ញើង

ខាងលិចប៉ែកខាងត្បូង នៅជញ្ជាំងថែវនោះ មានឆ្លាក់ជារូប ៨ កម្ពស់ប្រហែល ២ ម៉ែត្រ ជារូបលោកេស្វរៈច្រើនយ៉ាង ។

មានរូបពោធិសត្វដែលនេះមួយ និងព្រះពុទ្ធរូប ២ អង្គ គេបានរកឃើញក្នុងកន្លែងដែលបាក់បែក ។

ឃើញថារូបទាំងប៉ុន្មានដែលមានលើប្រាសាទនោះ ជារូបក្នុងព្រះពុទ្ធសាសនាទាំងអស់ លើកតែកន្លែងមួយចេញ គឺបន្ទប់ដែលមានក្រឡាខ្វែង ៤ ជ្រុង នៅខាងមាត់ទ្វារចូលទៅកំពែងខាងក្នុង បន្ទប់នោះ មានខ្លោងទ្វារឆ្លាក់ជារឿងព្រះឥសូរសុទ្ធ មានរូប ព្រះសិវ ១, ព្រះព្រហ្ម ១, និងព្រះវិស្ណុ ១, អង្គុយសំពះ ឯខ្លោងទ្វារឯទៀតនោះបែបមិនប្រាកដ ប៉ុន្តែវិមាននេះដែលនៅក្នុងចំណោមប្រាសាទធំ ។ នោះហាក់ដូចជាមានភាពជាគេមិនរាប់អាន ហើយនៅដោយចំណែកដាច់ពីប្រាសាទឯទៀត ដែលជាប្រាសាទសម្រាប់ពុទ្ធសាសនា ។

ម្យ៉ាងវិញទៀតឯជញ្ជាំងថែវនោះ ក្រៅពីរូបលោកេស្វរទាំង ៨ គ្មានអ្វីជាសម្គាល់ខាងផ្លូវសាសនាឡើយ គឺមានតែរឿងចម្បាំងជាក្បួនហែ និងរឿងការរបស់ស្តេច គេឃើញមានរឿងព្រាហ្មណ៍អង្គុយគោរពលិង្គ ១ ដែរ ប៉ុន្តែរឿងនេះគ្រាន់តែជាគុបតែងជាគំនូរប៉ុណ្ណោះទេ មិនបានជាការសម្រាប់គោរពរបស់អ្នកសាង ក៏ទេដែរ ។

ក្នុងទីនេះយើងឃើញរូបព្រះដែលមានសល់នៅអង្គរធំ ម្យ៉ាងវិញទៀត យើងឃើញរូបទាំងឡាយ ដែលពួកអ្នកគោរពរូបនៅអង្គរបានរាយចោល

កោសពោលនិងធ្វើឲ្យខុសកងចេញក្នុងក្រុងទាំងពីរនេះឃើញតែលោកកេស្វរជាប្រធាន លោកកេស្វរ នេះគេឃើញលេចភាពហាក់ដូចជាចៅហ្វាយនៃទីក្រុងនោះ ៗ អមរិន្ទ្របុរ និង យសោធរបុរ ជាទីក្រុងពីរមានភាពដូចគ្នា ហើយទីក្រុង ១ នៅមានសណ្ឋានជាទីក្រុងសម្រាប់ពុទ្ធសាសនា ឯទីក្រុង១ទៀតនោះបាត់អស់ខ្លះទៅ សេចក្តីដែលដូចគ្នានេះមានបញ្ជាក់ទៅដោយស្ថានផ្សេង ៗ ទៀត គឺនៅជញ្ជាំងខាងក្រោមកំពូលមុខបួននិងខឿនទ្រូបនាគ នៅខាងកើតទីក្រុងមានស្រះធំ ១ ពងបួនជ្រុងទ្រវែង ឯផែនទីក៏គ្មានសេចក្តីប្លែកជាលក្ខណ៍ គឺគ្រាន់តែប្លែកថា ក្រុងអង្គរធំនោះ មានទំហំផែនទីកបធំជាងបន្ទាយឆ្មារ ២ ដង ហើយ ១ ទៀតឯសីមានៃអង្គរធំនៅក្នុងកំផែងជុំវិញ ឯសីមានៃបន្ទាយឆ្មាវិញនោះនៅជាកណ្តាលកំផែងនិងដីទួល ដែលលើកសម្រាប់ការពារខាងក្រៅក្រុង ក្រៅពីសេចក្តីទាំងនេះអង្គរធំជាប្រាសាទមានភាពសុទ្ធនឹងបន្ទាយឆ្មា ជាក្រុង ១ យ៉ាងធំ យ៉ាងត្រឹមត្រូវតាមក្បួនខ្នាត ដែលបញ្ជាក់ដោយពិតអំពីអាណាចក្រដ៏ធំទូលាយរបស់ម្ចាស់ផែនដី ហើយដែលយើងហៅថារបៀបតាក់តែងក្រុងនិងរចនា ប៉ុន្តែបែបដែលកសាងទីក្រុង បែបដែលតុបតែងទីក្រុងមានភាពលំនាំមិនឆ្ងាយអំពីបែបភាពទីក្រុងជាន់មុន ៗ ឡើយ យើងសម្គាល់ឃើញសេចក្តីប្លែកបន្ទាប់បន្សំ ១ ទៀត តែមិននាំឲ្យប្រែប្រួលខូចយោបល់នេះទេ គឺថា

កោសបន្ទាយឆ្មារមានប្រាសាទតូច ១ សម្គាល់បានណាស់ឯអន្តរជំវិញនោះ គ្មានប្រាសាទតូចនេះឡើយ ប៉ុន្តែប្រាសាទតូចនេះឃើញមាននៅក្នុងប្រា-សាទធំៗ ដិតទីនោះសាងក្នុងគ្រាជាមួយ បានជាខ្ញុំនិយាយក្នុងស្ថាននេះឲ្យឃើញជាពិស្តារបន្តិច ព្រោះការកសាងនេះជាគោល១ដ៏ឧត្តមក្នុងពង្សាវតារ ហើយម្យ៉ាងទៀត ព្រោះខ្ញុំចង់តម្រូវសេចក្តីយល់ឃើញជាថ្មីអំពីរឿងនេះ ។

ប្រាសាទតូចៗទាំងនេះមានបណ្តោយពី ១២ ទៅ ១៥ ម៉ែត្រ សាងពីថ្មភក់ និងថ្មបាយក្រៀមក៏មានកម្រាស់ធ្ងន់ ប្រាសាទទាំងនេះមាន ៣ ចំណែក ខាងកើតមានយ៉ នៅកណ្តាលមានបន្ទប់វែង ១ ហើយខាងលិចមាន កន្លែងសន្និបាត ១ មានកំពូលខ្ពស់ឡើងសម្រាប់លោកកេស្វរ ដូចមាន ខ្លោងទ្វារជាសំគាន់ស្រាប់ ។ បន្ទប់វែងនោះមានពិតាន ១ សម្គាល់ឃើញពីខាងក្រៅ មានដំបូលកណ្តាល ១ និងថែវសងខាង ២ ហើយខាងក្នុង គេសម្គាល់ឃើញមានស្នាមខ្ពស់ទាប ហាក់ដូចជាគេបានបំបាត់សសរ ២ ជួរពោល ហើយរំលំជ្រុងចេញ គួរតែសម្គាល់ថា លើកតែត្រង់ព្រះបាទពិធូរចេញ នោះបន្ទប់នេះទទួលពន្លឺតែពីទិសខាងត្បូង ឯជញ្ជាំងខាងកើតនោះងងឹតសូន្យ គ្រាន់តែមានធ្វើបែបជាបង្អួចបញ្ឆោតប៉ុណ្ណោះ ។

សព្វថ្ងៃនេះ គេបានរកឃើញប្រាសាទធំៗ ១៥ យ៉ាងនេះ គឺប្រា-សាទព្រះខ័នទាំងពីរ តាព្រហ្ម, បេងមាលា និង បន្ទាយឆ្មា ឯប្រាសាទ

ឯទៀតនោះ រៀបគ្នាតាមបណ្ដោយតាមផ្លូវធំ ២ នៃស្រុកខ្មែរចាស់ គឺជាផ្លូវដែលចេញពីអង្គរធំទាំង ២ ហើយ ១ ឆ្ពោះទៅខាងកើតគឺចំពោះទៅព្រះខ័ន ១ ទៀតឆ្ពោះទៅទិសពាយព្យនោះចំទៅភីម៉ៃ ។

តាមធម្មតាប្រាសាទទាំងនេះឆ្ងាយពីគ្នា ពី ១៤ ទៅ ២០ គីឡូម៉ែត្រ ហើយនៅទៀងតែពីខាងជើងផ្លូវ គឺឲ្យយល់បានថា ប្រាសាទទាំងនេះទទួលពន្លឺតែពីទិសខាងត្បូង ហេតុនេះឲ្យយល់ឃើញថា ប្រាសាទទាំងនេះគេសាងតាមលំនាំផ្លូវ ទុកសម្រាប់អ្នកដំណើរ ។ បើគេពិចារណាឃើញថាប្រាសាទទាំងនេះសាងសម្រាប់លោកេស្វរ ហើយពោធិសត្វនេះ ជួនកាលមាននាមថា លោកេស្វរនៃមន្ទីរឱសថ គឺអរោគ្យសាលា នោះគេនឹងយល់ថា ប្រាសាទដែលសាងរៀបរៀងជាលំដាប់តាមផ្លូវនោះ ជាមន្ទីរព្យាបាលរោគ គឺអរោគសាលា សម្រាប់អ្នកដំណើរដែលឆ្ពោះទៅកាន់វិហារដ៏ប្រសើរ ប្រហែលជាទៅកាន់ប្រាសាទនៃលោកដ៏មានឥទ្ធិឫទ្ធិដែលកំចាត់បង់នូវទុក្ខបាន បើប្រសិនជាប្រាសាទទាំងនោះ គេសាងសម្រាប់ឧបត្ថម្ភមនុស្សជម្ងឺមែននោះ គេគ្មានសង្ស័យអ្វីឡើយ ដែលឃើញប្រាសាទទាំងនេះនៅក្នុងកំផែងក្រៅឆ្ងាយអំពីទីប្រជុំ ដើម្បីកុំឲ្យសៅហ្មងដល់សេចក្ដីបរិសុទ្ធ ។

ដោយជាការពិបាកនឹងនិរាករសេចក្ដីនឹងអធិប្បាយឲ្យចំប្រាកដ ហើយ

ដោយប្រាសាទនោះមានឈ្មោះផ្សេង ៗ ដូចជាប្រាសាទ ទ័ពជ័យ ដែល គេតែងតែកំណត់នាមដូច្នេះ នោះនាមនោះ ហាក់ដូចជាមិនមែនជាឈ្មោះ ពិតប្រាកដរបស់ប្រាសាទនេះឡើយ ហេតុដូច្នេះ យើងត្រូវតែតាំងនាម ដោយសន្មត កំណត់ហៅថា អរោគ្យសាលាវិញ លើកលែងតែក្នុង ស្ថានដែលអ្នកឯណា ១ បានរកស្គាល់ឃើញពិតប្រាកដ អំពីឈ្មោះ នៃប្រាសាទតាំងនេះ ដូច្នេះឃើញថាបន្ទាយឆ្មានោះ មានអរោគ្យសាលា ១ ឯអង្គរធំនោះគ្មានឡើយ ព្រោះថាប្រាសាទដែលនៅឃ្លាតដាច់ពីគេ នេះមិនជាសម្រាប់ត្រូវការដល់ទីក្រុងធំទេ ប៉ុន្តែគេឃើញមានអរោគ្យសា-លានេះក្នុងប្រាសាទផ្សេង ៗ ជិតទីនោះ គឺនៅប្រាសាទតាព្រហ្ម ប្រាសាទ ព្រះខ័ន និងក្នុងប្រាសាទមួយទៀត នៅដាច់ពីគេនៅក្នុងព្រៃជាខាងជើង ក្រុង គឺប្រាសាទផ្លូ តាមដែលបានពិនិត្យឃើញគេនឹងសម្គាល់បានថាប្រា-សាទបន្ទាប់បន្សំនេះ កើតក្នុងជាន់ដែលយើងហៅថា ជាន់រចនាប្រាសាទ បាយ័ន ហើយប្រាសាទនេះគេនឹងត្រូវការពិនិត្យជាក្រោយ នៅវេលា ដែលគេបានច្បាស់ នូវរឿងរ៉ាវអំពីប្រាសាទដែលសាងក្រោយ ៗ ដូចជា ប្រាសាទព្រះខ័នខាងកើត និងបេងមាលា ។

វេលានេះយើងត្រឡប់ទៅសេចក្តីខាងដើមវិញ គឺអំពីសាងអង្គរធំ ខ្ញុំ ស្មានថាបានពោលខាងដើមហើយ ថាអង្គរធំនោះ កាលដើមជាទីក្រុង

សម្រាប់ពុទ្ធសាសនា នៅក្នុងសេចក្ដីទំនុកបម្រុង នៃលោកស្ទើរដូចជាបន្ទាយឆ្មារដែរ ប៉ុន្តែប្រហែលជាស្ដេច ១ អង្គកាន់ពុទ្ធសាសនាបានសាង ឯស្ដេចនោះប្រហែលជាមិនមែនយសោវរ្ម័ន ដែលកាន់សាសនាព្រះឥសូរនោះឡើយ សេចក្ដីសន្និដ្ឋាននេះខ្ញុំមិនក្រេបទេ ច្បាស់ជាទាស់ខុសជាខ្លាំង អំពីចារឹកនៅស្តុកកក់ធំ តែយើងត្រូវពិនិត្យមើលឲ្យប្រាកដ ៗ

ចារឹកនេះធ្វើក្នុងសកពជ ៩៧៦ គឺក្នុងគ្រិស្តសកពជ ១០៥៤ កំណត់ ១០៥ ឆ្នាំ មុនឆ្នាំដែលយសោវរ្ម័នទិវង្គត ចារឹកនេះមិនមែនធ្វើសម្រាប់ចុះសេចក្ដីអ្វី ៗ ក្នុងជាន់នោះទាំងអស់ឡើយ ឯសេចក្ដីក្នុងនោះគឺស្រង់យកតាមគោលដើមមក ឯគោលនោះគឺជាបែបពង្សាវតារ ដែលគេកត់ត្រារៀង ៗ មកចំនួន ២៥០ ឆ្នាំ ប៉ុន្តែត្រូវបញ្ចូលក្នុងនេះគំនិតនិងប្រយោជន៍របស់បុរោហិតដែលបានតែងសេចក្ដីនោះ ក្នុងសំអាងយើងនោះថា នៅបន្ទាយបាយ័ន គេយកព្រះឥសូរជំនួសព្រះពុទ្ធ មិនត្រូវឆ្ងល់ឡើយពីក្រុមហោតា គឺក្រុមសង្ឃការីដែលយល់ឃើញថាជាការអាប់ឱនណាស់ ដែលយកព្រះខ្លួនទៅតម្កល់ក្នុងទីដែលគេសាងសម្រាប់ព្រះឯទៀតក្នុងស្រុកខ្មែរពីដើម សេចក្ដីនេះឃើញជាការប្លែកពីការអ្វី ៗ ទាំងអស់ ព្រោះគេមិនដែលកសាងបដិមាករឯណាមួយទៅតម្កល់ក្នុងប្រាសាទដែលគេបោះបង់ឡើយ តែត្រង់នេះស្ថានដែលបង្កើតឲ្យមានឡើង ដោយហេតុតែមាន

ប្រាសាទស្តេចនៅកណ្តាលនគរ តែជាដែលបង្កើតមានយ៉ាងដូច្នេះក៏មិនគួរដែរ រួចគេឃើញថាអយ្យកោរបស់សទាសិវចូលចិត្តបំបិទបំបាំងសេចក្តីដែលមិនល្អនេះឲ្យស្ងាត់ស្ងៀមទៅ យើងបន្ថែមថាឯប្រាសាទនោះ គេបានសង់ទៅសាសនាដើមវិញ ក្នុងរជ្យស្តេចកាន់ពុទ្ធសាសនាដែលគ្រងរាជ្យជាន់ក្រោយ ឯសេចក្តីអួតអាងរបស់ស្តេចយសោវរ្ម័ន សេចក្តីមានៈនិងគំនិតរបស់បុរោហិតនៃស្តេចនេះ ព្រមព្រៀងជាមួយគ្នា ហើយតាំងខ្លួនថាជាអ្នកដែលបានកសាងអង្គរធំនិងប្រាសាទបាយ័ន ប៉ុន្តែមានការ ១ នាំឲ្យទើសទែងទៅលើសេចក្តីនេះទៀត គឺអំពីរឿងការព្រះពុទ្ធដែលជាលំអទីគ្រងនោះ នៅលើកំពូលដំបូលនោះបានរៀបរៀងនូវពុទ្ធរូបទ្រង់ក្នុងជាជួរក្នុងក្បាំងដែលលកខួង តែរូបទាំងនោះគេរំលើងចោលអស់ នៅជញ្ជាំងនិងនៅសសរបាយ័ននោះដេរដាស ទៅដោយរូបព្រះពុទ្ធជាច្រើន ហើយរូបទាំងនោះគេគស់ចោលចេញគេរំលើងចេញ ឬ ក្លាយកងឲ្យទៅជាបែបតាបសមានពុកមាត់ ពុកចង្កាទៅវិញ ឬ ឆ្លាប់ធ្វើទៅជាលិង្គ ឬ ឆ្លាក់ជាបាច់ផ្កាតែមិនឃើញមានជាប់ពាក់ពាន់ដល់ទិអន្តរាយនោះទេ ដែលគេធ្វើនោះគឺធ្វើដោយពិនិត្យពិច័យដោយសេចក្តីព្យាយាមអត់ធ្មត់ត្រឹមត្រូវតាមទំនៀមទម្លាប់អ្នកស្រុក ការនោះប្រហែលជាធ្វើតាមបង្គាប់សេនាបតីម្នាក់ដែលបានចាត់ក្រសួងគមនាគារ ដោយយកប្រាក់ឃ្លាំងទៅចំណាយ គ្រានោះ

គួរឲ្យឃើញថ្ងូកដែលគេមិនបានបំបាត់រូបលោកេស្វរចេញ ព្រោះពោធិ-សត្វនេះមានដៃជើងនិងក្បាលច្រើន ដូចជាព្រះនារាយណ៍ឬព្រះឥស្វរដែរ ហើយគេទុករូបទាំងនេះជំនួសព្រះឥស្វរ និងព្រះនារាយណ៍នេះបានដោយងាយ ឯប្រាសាទខ្លះនៅអង្គរដែលមានពុទ្ធរូបជាច្រើនដែលលុបចេញមិនអស់នោះ ធ្វើឲ្យយើងឃើញជារឿងព្រះពុទ្ធសាក្យមុនី មានរឿងចេញពីនគរទៅទ្រង់ផ្នួស ឬត្រង់ដែលកាត់ព្រះកេសា រូបទាំងនេះ វេលាដែលឃើញគេអាចនឹងវិនិច្ឆ័យយកសេចក្តីអំពីពួកព្រាហ្មណ៍បានដោយងាយ ៗ

បើដូច្នេះឃើញថា យសោវរ្ម័ននេះមិនមែនជាអ្នកសាងអង្គរធំ និងបាយ័នឡើយ ថ្វីបើឃើញមានសេចក្តីអំនួត និងពាក្យរបស់ស្តេចនេះនិយាយបញ្ជាក់ ក្រៅពីសំអាងខាងផ្លូវសាសនានោះ យើងមានសំអាងយ៉ាងត្រឹមត្រូវដោយពិតនោះ ១ ទៀត គឺថា យើងមានប្រាសាទ ១ ដែលសាងក្នុងរាជ្យស្តេចយសោវរ្ម័ន គឺប្រាសាទភ្នំបាខែងដែលហៅថា យសោធរេស្វរ បើមាននរណា ១ យកប្រាសាទនេះទៅផ្ទឹមគ្នានឹងប្រាសាទបាយ័ននោះ អ្នកនោះនឹងបានសេចក្តីច្បាស់ក្នុងថា មិនមែនជាថ្វីដៃម្ចាស់ផែនដីជាមួយគ្នាឡើយ ៗ

សព្វនេះមិនមែនធ្វើគ្រាប់ឲ្យដូចទេ គ្រាន់តែជាការជួយណែអ្នកប្រែតារកនោះ ចេញពីថ្ម ៖

សព្ទ

មនព្រះបាទ បរមេស្វរ មកអំពីជ្វា បំក្រុងនិនៅនគរឥន្ទ្របុរីស្ដង់ អញ សិវៃកល្យ ត គឺប្រាជ្ញគរុជាបរោហិត តព្រះបាទបរមេស្វរ មនព្រះបាទថ្ងៃមកអំពីឥន្ទ្របុរ មនព្រះបាទបរមេស្វរក្រុងនីការ្យ នគរហរិហរក-លយ មនព្រះបាទបរមេស្វរ ទៅក្រុងនីការ្យមហេន្ទ្របវ៌ត មានព្រាហ្មណជះ ហិរណ្យទាមប្រាជ្ញសិទ្ធិវិទ្យា មកអំពីជនបទ បំព្រះបាទបរមេស្វរ អញ្ជញធ្វើពិធីលេហ លេងកំបីកម្ពុជទេស នេះអាយត្ត តជ្វាលើ លេងអាចតិ កម្រតេងផ្ទៃក្រោម ម្ស្យគុះតជា ចក្រវត្តិ ព្រាហ្មណនោះធ្វើពិធីដោយព្រះវិនាសិខប្រតិស្ឋាកម្រតេង ជគតតកជ ព្រាហ្មណនោះបង្រៀនព្រះវិនាសិខ នយោត្តរ សម្មោហ សិរច្ឆេទ ស្យង់មុខស្វតមុខ បុញ្ញបំ-សរសិរ បំប្រៀនស្ដេចអញ សិវៃកល្យនុតិ ប្រើស្ដេចអញ សិវៃកល្យគិតធ្វើពិធីនាកម្រតេងជគតតកជ មនព្រះបាទបរមេស្វរ ស្ដ័ចវិញមកក្រុងនិអាយនគរហរិហរកលយ ព្រះកម្រតេងអញតកជតិនាមមកឱកព្រះបាទបរ-មេស្វរ ស្ថិតនៅនគរ ហរិហរកលយ ។

បើថា យះសាវ្ម័ន មិនមែនជាអ្នកកសាងអង្គរធំ និងបាយ័នទេ នោះយើងត្រូវរកប្រអ្នកដែលកសាងនេះឲ្យឃើញ ដោយកប់រឿងតាមជួរក្រសែស្ដេចដែលគ្រងរាជ្យមុនៗ ។

ឥន្ទ្រវ្ម័នជាបិតាស្ដេចនេះ យើងមិនត្រូវយកមកនិយាយឡើយ ដោយ

ក្សត្រិយ៍នេះកាន់សាសនាព្រះឥស្សរយ៉ាងមាំមួនណាស់ ហើយប្រាសាទទាំងប៉ុន្មានដែលបានសាងនោះ សម្រាប់តែព្រះឥស្សរទាំងអស់ ម្យ៉ាងវិញទៀតឥន្ទ្រវរ្ម័ននេះ ជាវង្សក្សត្រិយ៍ថ្មីមិនជាប់ទៅក្នុងវង្សមុនឡើយ ។

វង្សក្រោយនេះមានតែស្តេចពីរព្រះអង្គ នាមជ័យវរ្ម័នទី ២ បរមេស្សរ (សកកាជ ៧២៤ ទៅ ៧៩១) ត្រូវនឹងគ្រិស្តសកកាជ ៨០២ ដល់ ៨៦៩ និងជ័យវរ្ម័នទី ៣ វិស្ណុលោកពីសកកាជ ៧៩១ ទៅដល់ ៧៩៩ ត្រូវនឹងគ្រិស្តសកកាជ ៨៦៩ ដល់ ៨៧៧ ស្តេចនេះកាន់សាសនាព្រះនារាយណ៍ (វិស្ណុ) ដូចមានព្រះនាមជាសម្គាល់ស្រាប់ ។

ជ័យវរ្ម័នទី ៣ គ្រងរាជ្យបានតិចណាស់ ទឹងសម្គាល់ថាជាអ្នកសាងអង្គរមិនបាន ។

រឿងក៏ប្រែផ្សេងទៅវិញកាលណា យើងរាប់ឡើងដល់ជ័យវរ្ម័នទី ២ បរមេស្សរ គឺថាត្រង់នេះយើងបានដឹងថា មានស្តេច ១ អង្គដែលមានឫទ្ធិ ហើយជាអ្នកសាងទីក្រុងជាច្រើនផង ។

ចារឹកនៅស្តុកកក់ធំដែលពណ៌នាពីស្តេចនេះ ដូចមានខាងក្រោយ ព្រះបាទបរមេស្សរយាងមកពីក្រុងជ្វា ដើម្បីគ្រងរាជ្យក្នុងឥន្ទ្របុរ ក្នុងវេលានោះមានគ្រូ សិវកៃវល្យជារាជបុរោហិត តពីនោះមក ព្រះបាទបរមេស្សរយាងទៅឯឥន្ទ្របុរ ហើយព្រះអង្គគង់នៅក្នុងហរិហរាលយ ទើបព្រះអង្គយាងទៅតាំងក្រុងអមរេន្ទ្របុរ ហើយទៅគង់នៅមហេន្ទ្របវ៌ត ក្នុងវេលា

នោះមានព្រាហ្មណ៍ ១ ឈ្មោះហិរណ្យទាម ជាអ្នកប្រាជ្ញក្នុងសិល្បវិទ្យា មកពីស្រុកជនបទ ព្រោះព្រះអង្គឲ្យទៅអញ្ជើញមកធ្វើពិធីដើម្បីកុំឲ្យក្រុងកម្ពុជា ជាចំណុះស្រុកជ្វា ហើយឲ្យមានក្នុងនគរនេះស្តេចចក្រវត្តិ ១ ព្រះអង្គ ព្រាហ្មណ៍នេះបានរៀបពិធីតាមដោយព្រះវិនាសិខ ហើយប្រតិស្ឋានស្តេចទេវរាជ (កម្រតេងជគតរាជ) ព្រាហ្មណ៍នេះបានបង្រៀន ព្រះវិនាសិខ នយោត្តរ សម្មោហ សិរច្ឆេទ ព្រាហ្មណ៍បានសូត្រតាំងពីដើមលុះចប់ ដើម្បីសរសេរ ហើយបង្រៀនដល់ស្តេចអញ សិវកៃវល្យ បានបង្គាប់ដល់សិវកៃវល្យ ឲ្យធ្វើពិធីនៃទេវរាជ វេលានោះព្រះបាទបរមេស្វរគ្រឡប់ទៅគង់ក្រុងហរិហរាលយវិញ ហើយបាននាំទេវរាជទៅទុកក្នុងទីនោះផង ព្រះបាទបរមេស្វរទិវង្គតក្នុងហរិហរាលយ ។

ឯពង្សាវតាររបស់ស្តេចនេះ គេសរសេរគ្មានថ្លុកថ្លង់ឡើយ ប៉ុន្តែអាចនឹងដកយកសេចក្តីដែលមានប្រយោជន៍បានគឺជ័យវរ្ម័ននិយាយក្នុងចារឹកថាព្រះអង្គយាងមកពីស្រុកជ្វា ឈ្មោះស្រុកនេះមិនច្បាស់សោះ (សព្វថ្ងៃខ្មែរតាំងឲ្យហៅឈ្មោះនេះ ដល់ប្រជុំស្រុកមាលយូ) ជ័យវរ្ម័នបាននិយាយពីមហានគរ ស្រីវិជ័យកាលក្នុងឆ្នាំ ៨០០ ទៅ ៩០០ អំពីដែលនគរនេះផ្សាយព្រះរាជអាណាខែត្រទៅលើតំបន់ខាងត្បូង បើមិនមែនផ្សាយខ្លួទៅលើតំបន់កោះជ្វាតាំងមូល ហើយថាក្នុងឆ្នាំនោះស្តេចស្រុកមាលាយូមករាយស្រុកខ្មែរមានជ័យទៀត ដូចមានរឿងកេរ្តិ៍របស់ អាប៊ុ-សាអ៊ីដហា-

សាន់នៅសៀកហ្វ៍ និយាយថាស្ដេចខ្មែរម្នាក់មកពីតំបន់បានជន ហើយប្រ-ហែលជាម្ចាស់ផែនដីស្រុកនោះដួយផង ដើម្បីមកដណ្ដើមយកកព្យនគរខ្មែរ ប៉ុន្តែគ្មានសេចក្ដីអ្វីជាពិតសោះ ឯនគរនេះកាន់ពុទ្ធសាសនាតាំងអស់ ហើយជឿគោរពលោកេស្វរ បើដូច្នេះហើយ យើងមានសំអាងជាច្រើនដែលនឹងពន្យល់រឿងរ៉ាវអង្គរធំបាន យើងត្រូវពិនិត្យតាមរឿងរ៉ាវស្ដេចដែលមកវាយយកស្រុកខ្មែរ ។

ស្ដេចនេះបានមកលុកលុយស្រុកខ្មែរ ហើយវាយដណ្ដើមយកបានក្រុងឥន្ទ្របុរ រួចពីនោះស្ដេចឡើងពីឥន្ទ្របុរទៅឯហរិហរាលយ តពីនោះទៀត ទ្រង់ស្ដេចទៅតាំងក្រុង អមរេន្ទ្របុរ គឺបន្ទាយឆ្មារ សាងលើមហេន្ទ្របព៌ត គឺភ្នំគូលែន ហើយត្រឡប់មកឯ ហរិហរាលយ វិញក៏ទិវង្គតទៅ យើងនឹងបន្ថែមថា នៅវេលាដែលសាងអង្គរធំហើយនោះ យើងមិនដឹងជាគេឲ្យឈ្មោះអ្វីសោះ សពាសិរមិនបានដាក់ឈ្មោះឲ្យយើងដឹង ព្រោះសពាសិរនេះចង់ឲ្យគេថាការកសាងនេះ ជាសំណាស្នាដៃរបស់សោ-វ៉ុនវិញ ដូច្នេះឃើញច្បាស់ប្រាកដថា ប្រាសាទតាំងប៉ុន្មានដែលជ័យវ៉ុន ២ បានសាងនោះ សុទ្ធតែជាប្រាសាទសម្រាប់ពុទ្ធសាសនាតាំងអស់ទី ហើយឧទ្ទិសថ្វាយដល់លោកេស្វរ ។ ចារឹកនៅស្ដុកកក់ធំនិយាយថាស្ដេចនេះបានឲ្យព្រាហ្មណ៍ម្នាក់មកពីស្រុកមិនបានកំណត់ឈ្មោះ ហៅថាជនបទមកបង្រៀនបុរោហិតស្ដេចនេះ អំពីវិជ្ជាតាំងឡាយផ្សេង ៗ ហើយបង្កើត

នូវការគោរពដល់ទេវរាជ ដើម្បីកុំឲ្យស្រុកខ្មែរចុះចូលស្រុកជ្វាទៀត ហើយឲ្យស្រុកខ្មែរនេះ មានស្តេចចក្រពត្រាធិរាជ ១ ។

រឿងនេះឃើញជារឿងតែឯង ប៉ុន្តែបើទុកជារឿងដូច្នេះ ក៏គង់តែចូលជាពង្សាវតារដែរ គេនឹងមិនយកក្បួនដែលមានពាក្យឈ្មោះនេះជាប្រយោជន៍ក៏បាន ក្បួននេះពាក់ជាអក្សរគេត្រូ ដែលគេមិនស្គាល់សោះនៅក្នុងស្រុកឥណ្ឌា ហើយដែលមានចំណងជើងរឿង ។ គឺវិនាសិខនយោត្តរ សម្មោហ សិរស្នេទ នោះឃើញថាក្បួនទាំងនេះ មានលាយធម៌សាប៊ិខ្លះ មន្តអាគមខ្លះ ហើយគឺគមានជាប្រើនក្នុងសាសនាដែលកើយរឿងទៅ ការដែលជាធំនោះ គឺដែលបានប្រតិបត្តិគោរពនូវលិង្គ ដើម្បីឲ្យបាននគរខ្មែរជាឯករាជ្យ ឯនាមចក្រពត្រានោះ ជាតម្លៃណាស់ គឺជាអធិរម្ចាស់ផែនដីដែលមានក្រស័ត្រជាច្រើននៅក្នុងអំណាច ហើយម្ចាស់ផែនដីនោះ គ្មានលុះអំណាចផែនដីណាមួយសោះ ។

វេលាដែលយសោវរ្ម័នទី ២ ឡើងគ្រងរាជ្យនោះ ព្រះអង្គនៅក្នុងអំណាចផែនដីជ្វា (អាយត្ត) គឺថាជាក្រស័ត្រចំណុះមហារាជនៅស្រីវិជ័យដោយជាចំណុះតាំងពីដើមមក ហើយមកគង់នៅក្នុងស្រុកខ្មែរជាក្រោយ ឬដោយព្រោះតែស្រុកខ្មែរចុះនឹងចាញ់មហារាជដែលពោលហើយនេះ ដូចជាអាប៊ុសារនឹងបាននិទានទុក ស្តេចនេះមានប្រាថ្នានឹងផ្តាច់ចំណងដែលចងនូវគេចេញ ប៉ុន្តែបុះហេតុដូចម្តេច បានជាការដែលគ្រាន់តែគោរព

ព្រះ១ថ្មី នោះ អាចនឹងនាំឲ្យស្តេចនេះ សម្រេចតាមគំនិតបាន? យើងស្មានថា សេចក្តីនេះនឹងពន្យល់បាន ព្រះនេះដែលជាលិង្គ ១ ឈ្មោះថា កម្រតេងជគតរាជ នោះមិនមែនប្រាកដជាឈ្មោះដែលមាននិយាយក្នុងចារឹកនៅស្តុកកក់ធំនោះទេ ឯចារឹកធ្វើឲ្យយើងដឹងថាព្រះនោះ ទំនុកបម្រុងនូវអំណាចម្ចាស់ផែនដី តៗ គ្នា (គិតតាំងពីរាជ្យកម្រតេងផ្ទៃក្រោមប្រពានមក)ៗ

គេនឹងយកលិង្គនេះធៀបនឹងលិង្គភទ្រេស្វរនៅស្រុកមីសឹន ដែលព្រះឥសូរឲ្យមកស្តេច ដែលគ្រងរាជ្យជាដំបូងនៅស្រុកចម្ប៉ាបាន ដែលគេទុកជា ខ្លឹមនៃរាជានុភាពរបស់រាជវង្ស ៗ គ្នា (សន្តតិរាជ្យរហូតភទ្រេស្វរ) ឯស្តេចដែលគោរពដល់លិង្គនេះ នោះបានទទួលនាមផ្ទាល់ពីស្ថានសួគ៌មក មិនមែនទទួលពីស្តេចឯណា ១ ឡើយ គឺបានជាស្តេចចក្រវត្តិដោយអំណាចទិព្វ ដោយហេតុនេះហើយបានជាជ័យវរ្ម័នទី ២ ដែលចង់តាំងខ្លួនជាឯករាជ បានសាងរូបទេវរាជនេះ ក្នុងនគរព្រះអង្គ ៗ

តើក្នុងស្ថាននេះ យើងត្រូវជឿថា ស្តេចនេះបោះបង់ពុទ្ធសាសនាបោលទៅកាន់សាសនាព្រះឥសូរវិញឬអ្វី ត្រង់នេះដូចជាគ្មានប្រយោជន៍ប៉ុន្មានទេ ព្រោះគេអាចនឹងទុកសាសនាចាស់ សម្រាប់គោរពបានផង ហើយទៅបូជាព្រះថ្មីបានឥតខាសអ្វីផង ៗ

ស្តេចស្រុកខ្មែរទាំងឡាយ តាមធម្មតា ច្រើនតែមានអធ្យាស្រ័យ ហើយមិនគិតថា ខុសអំពីសេចក្តីដែលគោរពប្រតិបត្តិ ដល់ព្រះឥសូរជា

មួយនឹងព្រះពុទ្ធ ។

ម្យ៉ាងវិញទៀត ពួកអាចារ្យ ដែលនៅក្នុងបង្គាប់ស្ដេច ក៏មានបញ្ញាចេះប្រមូលសេចក្ដីជឿមិនឲ្យទាស់ទែងគ្នាបាន ឯព្រះរាជបុត្រជ័យវរ្ម័នទី ២ នោះក៏គោរពដល់ទេវរាជដែលជាសាសនាព្រះឥសូរដែរ ពិតមែនតែទ្រង់កាន់សាសនាព្រះនារាយណ៍ ។

សេចក្ដីសន្និដ្ឋានទាំងប៉ុន្មានដែលពោលមកនេះ នាំយើងមកដាក់នៅចុះសេចក្ដីដែលគេស្មានថាលំពិតបានហើយ ។ ត្រូវតែយកមកសើរើវិញក្នុងវេលានេះ ។ ក្នុងប្រាសាទខ្លះដែលស្ដេចជ័យវរ្ម័នបានសាងនោះ គេឃើញមានកំពូលមុខ ៤ ជាច្រើន យើងបានពន្យល់មុននេះបន្តិចពីកំពូលទាំងនេះ ថាគេបានធ្វើប្រែកទៅជាលិង្គមុខ ៤ វិញ ហើយសេចក្ដីពន្យល់នេះក៏បានយល់ព្រមព្រៀងគ្នាមក ។

សេចក្ដីពន្យល់នេះ បានយល់ព្រមថា ទាំងបន្ទាយឆ្មារ ទាំងបន្ទាយបាយ័ន និងប្រាសាទឯទៀតផ្សេងៗ ដែលមានសណ្ឋានប្រហែលគ្នានោះជាថ្មីដែររបស់យសោវរ្ម័ន ដែលជាស្ដេចកាន់សាសនាព្រះឥសូរ ហើយគោរពប្រតិបត្តិដល់លិង្គនោះ ប៉ុន្តែសេចក្ដីពន្យល់នេះឃើញមិនពិតជាច្រើន ប្រសិនបើប្រាសាទទាំងនេះជាការថ្មីដែររបស់ស្ដេច ១ អង្គ ដែលកាន់ពុទ្ធសាសនាវិញ ។

តើខុសត្រង់យ៉ាងណាទៅ ប្រសិនបើជាថារូបមុខ ៤ នោះជារូបរបស់លោកេស្វរវិញ ដោយហេតុថារូបដែលមានមុខច្រើនយ៉ាងនេះមិនសូវក្រ

ប៉ុន្មានទេ ពិតមែនតែគំរូមុខនេះមិនជាឃើញញឹកញយ តែថាក្នុងស្ថាននេះ
យើងគួរបញ្ចូលទៅជាទំនងការអលង្ការវិញ ម្យ៉ាងវិញទៀតគួរយល់ថាមុខ
៤នេះ ជាមុខដែលបែរក្រឡេកទៅគ្រប់ទិសទាំងអស់ភ្លាម ៗ ដើម្បីឲ្យពារ
សព្វសាធុការ ជាជាងដែលយល់ថាជាក្បាលដែលមានមុខ ៤ នោះវិញ
បានជាថាដូច្នេះ ព្រោះជាមុខដែលមាននៅប្រាសាទបន្ទាយឆ្មារនោះឃើញ
មានមុខផ្សេង ៗ មកជ្រៀតនៅជាកណ្ដាលនៃមុខ ៤ នោះទៀត ហើយ
ដូចជាមុខដែលមាននៅប្រាសាទស្ទឹង ជិតប្រាសាទព្រះខ័ន ខាងកើត
នោះក៏ឃើញមានទំនងអលង្ការអ្វីមកជ្រៀតនៅចន្លោះមុខ ៤ នោះដែរ ក្នុង
ស្ថានទាំងនេះហាក់ដូចជាគេចង់ឲ្យឃើញតែមុខ ១ ដាច់ពីគេកុំឲ្យជាប់នឹង
ក្បាច់អលង្ការឯទៀត ឯសេចក្ដីយល់ឃើញរបស់ខ្ញុំថា អង្គរធំនិងប្រាសាទ
កណ្ដាលគឺប្រាសាទបាយ័ននោះ ស្ដេចជ័យវរ្ម័នទី ៦ បរមេស្វរបានសាង
ក្នុងឆ្នាំ ៨៩០ គឺ ៩០ ឆ្នាំមុនឆ្នាំដែលគេធ្លាប់ជឿមក ប្រាសាទបាយ័នកាល
ដើមថ្វាយដល់ពុទ្ធសាសនា ហើយតមកស្ដេចដែលនេះ បានដាក់ទៅជា
សម្រាប់លិង្គវិញ គឺពីសេចក្ដីផ្លាស់ប្ដូរសាសនានេះមក ពុទ្ធរូប ឬ រឿងក៏
ក្នុងពុទ្ធសាសនាទាំងឡាយនៅអង្គរធំ គេបានវាយចោលក៏មិនដឹង ហើយ
ប្រាសាទបន្ទាប់បន្សំឯទៀត ដែលជាប្រាសាទសម្រាប់សាសនាព្រះឥសូរ
នោះ បានសាងបន្ថែមជាក្រោយនៅក្នុងទីបាយ័ន ខ្ញុំមិនមែនអួតថាសំអាង
ខ្ញុំនេះ ការបំបាត់នូវសេចក្ដីសង្ស័យ ហើយបំភ្លឺនូវសេចក្ដីងងឹតគ្រប់ស្ថាន
បានឡើយ ដែលខ្ញុំនិយាយនេះ គឺថាក្នុងការដែលកំពុងធៀបរកសព្វ

ថ្ងៃនេះ សេចក្ដីយល់ឃើញរបស់ខ្ញុំ ហាក់ដូចជាឃើញពិតជាងសេចក្ដីឯទៀត ក្នុងការដែលបានដឹងស្គាល់ ក្នុងពួកសេចក្ដីទាំងនេះ មានសេចក្ដី ១ ឥតមានសន្ទិះសង្ស័យឡើយ គឺអំពីដែលព្រះពុទ្ធសាសនារុងរឿងចំរើនណាស់ ក្នុងជាន់ដែលគេកប់អានក្បាច់អលង្ការក្នុងនគរខ្មែរ កាលជាន់ដើម គឺព្រោះតែជឿពុទ្ធសាសនានេះហើយ បានជាស្រុកខ្មែរកាលក្នុងឆ្នាំ ៩០០ មានសាងប្រាសាទដេរដាស ដូចកាលនគរបាកំងសែសក្នុងឆ្នាំ ១១០០ ដែរ មិនជាចាស់ទេដែលកប់បញ្ចូលប្រាសាទខ្លះក្នុងជាន់ដើម ដែលធ្វើពីថ្មបាយក្រៀមផង ឯព្រះដែលសម្រាប់សាសនាក្នុងស្រុកខ្មែរក្នុងដើមឆ្នាំ ៩០០ នោះ មិនមែនជាហរិហរក្នុងជាន់ដំបូង ឬព្រះឥសូរក្នុងជាន់តមកឡើយ គឺជារូបលោកេស្វរដែលមានមុខច្បាស់ ហើយញញឹមមានមេត្តាទៅរកសេចក្ដីឈឺចាប់និងទុក្ខភ័យរបស់មនុស្ស គឺថាជាតួអង្គពោធិសត្វ ដែលអ្នកកាន់ពុទ្ធសាសនាឲ្យនាមថាព្រះមហាករុណា ។ ជាក្រោយដែលសាសនាព្រាហ្មណ៍ មកលុកលុយសង្កត់សង្កិនកំណត់ ៣ ឆ្នាំនោះ ពុទ្ធសាសនាចំរើនឡើងវិញ ក្នុងរជ្ជជ័យវរ្ម័នទី ៦ ដែលមានកិរិយាប្រហែលគ្នានិងជ័យវរ្ម័នទី ១ ព្រោះជាអ្នកច្បាំងច្រើន ជាអ្នកសាងប្រាសាទច្រើន សាងទីព្យាបាលរោគច្រើនដូចគ្នា បើដូច្នេះឃើញថាសម័យដែលរុងរឿង ២ ដង ក្នុងពង្សាវតារខ្មែរនោះ គឺនៅក្នុងសម័យពុទ្ធសាសនាទាំងអស់ ហើយគេនិងបញ្ចប់សេចក្ដីយល់ឃើញអំពីរឿងនេះ បានថាសាសនាសព្វថ្ងៃនេះ ដែលអ្នកស្រុកស្រឡាញ់ណាស់ មិនមែន

ទើបនឹងនាំយកពីស្រុកក្រៅមកទេ ប៉ុន្តែដោយគ្មានសាលា នឹងសិក្សាសាសនានេះ ក៏កប់ឫសចុះទៅក្នុងគំនរយ៉ាងជ្រៅនៃរឿងរ៉ាវក្នុងនគរ ។

(ចប់តែប៉ុណ្ណោះ)